ខុមហ្វ្រែល COMFREL

# របាយការណ៍
# សង្កេតដំណើរការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦






ខែកុម្ភៈ ឆ្នាំ២០១៧

# មាតិកា


បុព្វកថា.......................................................................................................................................................១

ការសន្និដ្ឋាន និងសង្ខេបការរកឃើញ ........................................................................................................... ២

១. សេចក្តីផ្តើម ................................................................................................................................................ ៣

២. សង្ខេបក្របខណ្ឌច្បាប់ទាក់ទងការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦.........................៨

ក. របាយការណ៍សង្កេតទូទៅអំពីដំណើរការចុះឈ្មោះបោះឆ្នោត ...................................................................១២

ខ. ការឃ្លាំមើលលើបទបញ្ជា និងនីតិវិធីក្នុងដំណើរការចុះឈ្មោះបោះឆ្នោត .......................................................២៦

គ. ការរកឃើញរបស់ គ.ជ.ប អំពីភាពមិនប្រក្រតី និងទិន្នន័យខុស.................................................................. ៣៦

ឃ. ការវាយតម្លៃជាទូទៅនៃការឃ្លាំមើលដំណើរការចុះឈ្មោះបោះឆ្នោតពីអ្នកសង្កេតការណ៍ ............................. ៣៩

ឧបសម្ព័ន្ធ ......................................................................................................................................................៤០

## បុព្វកថា

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា (ខុមហ្វ្រែល) ក្នុងកិច្ចសហការជាមួយសមាជិកនៃ សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) បានចូលរួមធ្វើការសង្កេត/ ការអង្កេត ការចុះឈ្មោះការបោះឆ្នោត និងតាមដានលើការដោះស្រាយលើដំណើរការការចុះឈ្មោះបោះឆ្នោតផងដែរ។ ការចុះឈ្មោះបោះឆ្នោតថ្មី គឺបានប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ។ ការសង្កេត/ការអង្កេតលើដំណើរការចុះឈ្មោះបោះឆ្នោតគឺត្រូវបានបញ្ចូលលើការបិទផ្សាយបញ្ជីដំបូង និងបណ្តឹងទាក់ទងលើភាពមិនប្រក្រតីនៃបញ្ជីបញ្ជីបោះឆ្នោតដំបូងផងដែរ។

ខុមហ្វ្រែល (COMFREL) ក្នុងកិច្ចសហប្រតិបត្តិការជាមួយ សមាជិកសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) បានជ្រើសរើសវគ្គបណ្តុះបណ្តាល និងដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន ៥៤៦នាក់ ដើម្បីធ្វការសង្កេតលើដំណើរការចុះឈ្មោះដែលមានរយៈពេលពី ៣ថ្ងៃ រហូតដល់ ១២ថ្ងៃ។ ការដាក់ពង្រាយអ្នកសង្កេតការណ៍នេះ គឺមិនមានលទ្ធភាពដាក់ពង្រាយគ្រប់ក្រុមចុះឈ្មោះអ្នកបោះឆ្នោតក្នុង ១៦៣៣ឃុំ សង្កាត់ និងគ្រប់តាមកាលវិភាគចំនួន ៩0ថ្ងៃ (ចាប់ពីថ្ងៃទី ១ ខែកញ្ញា ដល់ថ្ងៃទី៣0 ខែវិច្ឆិកា ឆ្នាំ២០១៦) នោះទេ។

ទោះបីយ៉ាងណាខុមហ្វ្រែល មានមោទនភាព និងសេចក្តីរីករាយយ៉ាងខ្លាំង ដល់គ្រូបង្គោល អ្នកសង្កេតការណ៍ និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូមួយចំនួនដូចជា គណៈកម្មាធិការអព្យាក្រឹត្យ និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (និកហ្វិច/NICFEC) មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (ភីឌីភី/PDP) អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន ( YRDP) អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងប្រតិបត្តិការសង្កេត ក្នុងដំណើរការចុះឈ្មោះបោះឆ្នោតនេះ។

ខុមហ្វ្រែល ជាមួយសមាជិកនៃសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) ក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅនូវការផ្តល់សហប្រតិបត្តិការ ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គណបក្សនយោបាយសំខាន់ៗ មួយចំនួន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលបានចូលរួមសហការ។

ខុមហ្វ្រែល និងសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) ក៏សូមថ្លែងអំណរគុណ ដល់ម្ចាស់ជំនួយដូចជា វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI), SDC ( Swiss Development Cooperation ), Diakonia, អង្គការ NPA (Norwegian People's Aid), OSI ដែលមានបានគាំទ្រគម្រោងទាក់ទងការឃ្លាំមើលដំណើរការចុះឈ្មោះបោះឆ្នោត។

ជាពិសេស ក្រុមការងាររបស់ខុមហ្វ្រែល ដែលបានរៀបចំផែនការ គ្រប់គ្រង និងចងក្រងវិធីសាស្ត្រនៃគម្រោងដែលមានរាយនាម ដូចជា៖ លោក កន សាវាង្ស លោក គឹម ឈន លោក ស៊ិន ទិត្យសីហា លោក យឿង សុធារ៉ា លោក សៀន ប៊ុនរិទ្ធិ អ្នកស្រី សៀង ដាលីយ៉ា អ្នកស្រី ភួង សុខកា លោក មាស សិរីសោភ័ណ លោក សួន យុធ្យា លោក ផាត សុភ័ក្រ្ត លោក នាង សុវណ្ណ លោក ជន ចាន់រ៉ែន អ្នកស្រី សឺន កេតសិរីលក្ខ លោកស្រី ម៉ៅ ផល្លី ក្រោមការដឹកនាំរបស់លោក គល់ បញ្ញា នាយកប្រតិបត្តិ អង្គការខុមហ្វ្រែល។

# ការសន្និដ្ឋាន និងសង្ខេបការរកឃើញ

១. លទ្ធផលនៃការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ បានចុះឈ្មោះប្រមាណ ៧.៨៧លាននាក់(៨១.៤៧%)ក្នុងចំណោមអ្នកមានសិទ្ធិចុះឈ្មោះ ៩.៦លាននាក់ ដែលមិនបានពេញលេញ(សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតយល់ថាយ៉ាងតិចក៏ ៩៥% នៃអ្នកមានសិទ្ធិបោះឆ្នោត)។ អ្នកមានសិទ្ធិបោះឆ្នោតនៅសល់មួយចំនួនក៏នៅចង់មកចុះឈ្មោះបោះឆ្នោត បន្ទាប់ពីការបិទការចុះឈ្មោះបោះឆ្នោតនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០១៦។

២. ដំណើរការរៀបចំការចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅតាមបទបញ្ញា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត និងផែនការរបស់ គ.ជ.ប ដែលអាចទទួលយកបាន បើទោះបីមានភាពមិនប្រក្រតីខ្លះ។

- ការជ្រើសរើសមន្ត្រីចុះឈ្មោះបោះឆ្នោតមានការចូលរួមពីសមាជិក គ.ជ.ប និងការបើកចំហ និងតម្លាភាពជាងការជ្រើសរើសមន្ត្រីពីមុន ហើយមន្ត្រីទាំងនោះមានការខិតខំបំពេញភារកិច្ច។
- ការបង្កើតការិយាល័យបោះឆ្នោតភាគច្រើនមានលក្ខណៈត្រឹមត្រូវទៅតាមស្ថានភាពភូមិសាស្ត្រដង់ស៊ីតេប្រជាពលរដ្ឋនៅតាមភូមិឃុំសង្កាត់ និងបទបញ្ញានីតិវិធីចុះឈ្មោះបោះឆ្នោត ប៉ុន្តែមានការបង្កើតការិយាល័យ និងការចេញលិខិតបញ្ជាក់ទីលំនៅដល់នគរបាល និងយោធិន ដែលអាចត្រូវបកស្រាយជាបញ្ហាទាក់ទិននយោបាយនៅក្នុង ១៩ឃុំ និងក៏អាចប៉ះពាល់ដល់ភាពសម្ងាត់នៃក្រុមចុះឈ្មោះជាកងកម្លាំងប្រដាប់អាវុធ ពិសេសយោធា។
- ក្រុមប្រជាពលរដ្ឋពិសេសអ្នកចំណាកស្រុកនៅក្រៅប្រទេស ព្រះសង្ឃមិនអាចមក ឬនិមន្តចុះឈ្មោះបានច្រើនដែលបញ្ហាសំខាន់ពួកគេ គ្មានព្រះឆាយាលក្ស ឬការណែនាំមិនត្រឹមត្រូវអំពីសិទ្ធិចូលរួមរបស់ព្រះសង្ឃ និងគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ខ្វះលទ្ធភាពមធ្យោបាយធ្វើដំណើរ ឬនិមន្ត និងគ្មានពេលវេលា។
- មានការរារាំង និងការមិនលើកទឹកចិត្តចំពោះការអប់រំ និងការផ្សព្វផ្សាយព័ត៌មានការចុះឈ្មោះបោះឆ្នោតដោយអាជ្ញាធរ។
- មិនមានភាពប្រក្រតីធ្ងន់ធ្ងរ និងបណ្តឹងច្រើនទេក្នុងអំឡុងការសង្កេតដំណើរការចុះឈ្មោះបោះឆ្នោត តែក្នុងចំណោមភាពមិនប្រក្រតីសរុបចំនួន ១៥៥៤០ករណី (ចំនួនអ្នកសង្កេតការណ៍សរុប ៥៤៦នាក់ មកពីខុមហ្វ្រែល សហការជាមួយសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត ហៅថា ERA មានដូចជា អង្គការនិកហ្វិក អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន) ភាពមិនប្រក្រតីកើតច្រើន ដែលគួរឲ្យយកចិត្តទុកដាក់នោះ គឺការបញ្ចូលទិន្នន័យខុស និងការមិនពិនិត្យ និងផ្ទៀងផ្ទាត់ឈ្មោះ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។ ក្រុមប្រឹក្សាឃុំសង្កាត់ក៏ខិតខំដោះស្រាយបណ្តឹងបាន ៥០% នៃ ៥២៣ពាក្យបណ្តឹង ដែលមានការទទួលពាក្យបណ្តឹង និងបដិសេធបណ្តឹងមិនច្រើន។

៣. សម្រាប់ប្រព័ន្ធចុះឈ្មោះបោះឆ្នោតថ្មី គ.ជ.ប មានសមត្ថភាពក្នុងការផ្ទៀងផ្ទាត់ ហើយរកឃើញភាពមិនប្រក្រតីឈ្មោះស្ទួនជា២ម៉ឺនឈ្មោះ និងកំហុសទិន្នន័យប្រមាណ ៣% នៃអ្នកបានចុះឈ្មោះបោះឆ្នោតតែប្រព័ន្ធនេះក៏អាចកែតម្រូវផងដែរ។

៤. នៅក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ឃើញថាប្រជាពលរដ្ឋប្រហែល ៣០% បានមកពិនិត្យផ្ទៀងផ្ទាត់ឈ្មោះនៅសាលាឃុំ សង្កាត់ ជាមួយនិងការសង្កេតឃើញថាឃុំ សង្កាត់មួយចំនួន នៅមានបាត់បង់ឈ្មោះដែល គ.ជ.ប មិនទាន់បញ្ចូលទៅក្នុងបញ្ជីឈ្មោះនៅឡើយ។

# ១. សេចក្តីផ្តើម

## ១.១ ការវិវត្តន៍នៃប្រព័ន្ធចុះឈ្មោះបោះឆ្នោតនៅក្នុងប្រទេសកម្ពុជា

នៅក្នុងសម័យបោះឆ្នោតឆ្នាំ១៩៩៣ បញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវបានរៀបដោយអង្គការសហប្រជាជាតិ (UNTAC)។ ប្រជាពលរដ្ឋមានសិទ្ធិចុះឈ្មោះបោះឆ្នោត និងបោះឆ្នោតនៅទីកន្លែងណាក៏បាន។ អ្នកចុះឈ្មោះបោះឆ្នោតម្នាក់មានកាតមួយប្រើប្រាស់សម្រាប់ការបោះឆ្នោត ក្រោយពីបានចុះឈ្មោះហើយ ដោយកាតប្រើប្រាស់សម្រាប់ប្រើបោះឆ្នោតនោះមានរូបថតបន្ថែមលើព័ត៌មានផ្ទាល់ខ្លួន។

មកដល់ឆ្នាំ១៩៩៨ ប្រព័ន្ធចុះបោះឆ្នោតត្រូវបានធ្វើការកែសម្រួលថ្មី ដោយអ្នកចុះឈ្មោះបោះឆ្នោត រស់នៅក្នុងឃុំសង្កាត់ណាត្រូវទៅចុះឈ្មោះ និងបោះឆ្នោតនៅកន្លែងនោះ។ ការចុះឈ្មោះបោះឆ្នោតត្រូវបានប្រើប្រាស់ឯកសារជាច្រើនប្រភេទមានដូចជា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សំបុត្រកំណើត សៀវភៅគ្រួសារ លិខិតឆ្លងដែនជាដើម។ អ្នកចុះឈ្មោះ មិនមានឯកសារ នោះអ្នកត្រូវសុំឯកសារបញ្ជាក់អត្តសញ្ញាណដោយនាំជាមួយសាក្សី ២នាក់ទៅសាលាឃុំសង្កាត់ ដែលក្រោយមកកែ ហៅថាទម្រង់១០១៨ ឬ ប័ណ្ណខៀវ។ អ្នកគ្រប់គ្រងដំណើរការចុះឈ្មោះបោះឆ្នោតនេះត្រូវបានទទួលភារកិច្ចដោយក្រុមប្រឹក្សាឃុំ សង្កាត់ ជាពិសេសប្រធានឃុំ ចៅសង្កាត់ និងស្មៀនឃុំ សង្កាត់ ជាអ្នកទទួលខុសត្រូវចុះឈ្មោះជូនអ្នកបោះឆ្នោត។

## ១.២ ហេតុអ្វីត្រូវការមានប្រព័ន្ធចុះឈ្មោះបោះឆ្នោតថ្មី

ចាប់ពីឆ្នាំ១៩៩៨ រហូតដល់ការបោះឆ្នោតឆ្នាំ២០១៣ បញ្ជីឈ្មោះបោះឆ្នោតតែងតែជួបនូវបញ្ហា និងកើតឡើងនូវភាពមិនប្រក្រតីជាច្រើន ដូចជាការបាត់បង់ឈ្មោះពីក្នុងបញ្ជីបោះឆ្នោត បញ្ជីឈ្មោះមានឈ្មោះស្ទួន មានឈ្មោះតែមិនមានអ្នកស្គាល់ ឬមិនមានមនុស្សក្នុងទីតាំងការិយាល័យទាំងនោះ ជាពិសេសការចុះឈ្មោះដោយមិនមានសាមីខ្លួនទៅចុះដោយផ្ទាល់ ភាពមិនប្រក្រតីនៃការចុះឈ្មោះឲ្យជនបរទេសជាដើម។ ករណីទាំងអស់នេះត្រូវបានរកឃើញដោយអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ព្រមទាំងគណបក្សនយោបាយ ដែលធ្វើឲ្យមានការតវ៉ាក្នុងពេលបោះឆ្នោតម្តងៗ ជាពិសេសការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥ ឆ្នាំ២០១៣។

បញ្ហាទាំងអស់នេះ ឈានទៅរកការចរចារ និងព្រមព្រាងនយោបាយរវាងគណបក្សដែលមានអាសនៈក្នុងរដ្ឋសភាគឺគណបក្សប្រជាជនកម្ពុជា ជាគណបក្សកាន់អំណាច (គណបក្សមតិភាគច្រើន) និងគណបក្សសង្គ្រោះជាតិ ជាគណបក្សនៅក្រៅរដ្ឋាភិបាល (គណបក្សមតិភាគតិច) ដែលព្រមព្រាងធ្វើកំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងបញ្ជីឈ្មោះបោះឆ្នោតថ្មី នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។

## ១.៣ ការរកឃើញពីការសាកល្បងប្រព័ន្ធចុះឈ្មោះបោះឆ្នោតដោយសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត

ក្នុងឆ្នាំ២០១៥ ខុមហ្វ្រែល រួមជាមួយសមាជិកសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត បានសហការគ្នារៀបចំប្រព័ន្ធចុះឈ្មោះបោះឆ្នោតសាកល្បង និងអនុវត្តន៍ការសាកល្បង ដោយប្រើប្រាស់កុំព្យូទ័រ ជាមួយការចុះឈ្មោះ "នៅនឹងកន្លែង" (ចុះនៅទីកន្លែងណាបោះឆ្នោតនៅទីកន្លែងនោះ) មានចំនួន ២ឃុំ នៅក្នុងខេត្តរតនគីរី កំពង់ឆ្នាំង និងការចុះឈ្មោះបោះឆ្នោត "នៅកន្លែងផ្សេង" (ការចុះឈ្មោះខុសពីកន្លែងបោះឆ្នោត) នៅក្នុងរាជធានីភ្នំពេញ(ចំនួន ពីរទីតាំង) សរុបចំនួន ៦៥២នាក់ នៃអ្នកចុះឈ្មោះ។

ការសាកល្បងបានរកឃើញនូវចំណុចសំខាន់ៗ ដូចខាងក្រោម:

១. យុវជនពិតជាមានសមត្ថភាពដែលជ្រើសរើសបាននៅក្នុងមូលដ្ឋាន មានអាយុចន្លោះពី២០ ទៅ ៣០ឆ្នាំ ដែលបានក្លាយជាមន្ត្រីស្ម័គ្រចិត្ត និងប្រើប្រាស់កុំព្យូទ័របាន។ ការបញ្ចូលទិន្នន័យរបស់មន្ត្រីស្ម័គ្រចិត្តសម្រាប់អ្នកសុំចុះ

ឈ្មោះ មានភាពត្រឹមត្រូវនៃទិន្នន័យ ចំនួន ១០០% នៃអ្នកបានចុះឈ្មោះទាំងអស់ប្រៀបធៀបជាមួយទិន្នន័យនៃឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះ។

២. ការចុះឈ្មោះសាកល្បងប្រើរយៈពេលជាមធ្យមអស់ ៥នាទី ក្នុងអ្នកចុះឈ្មោះម្នាក់ ដែលតិចជាងលទ្ធផលគ្រោងទុករយៈពេល ៧នាទីក្នុងការចុះឈ្មោះអ្នកបោះឆ្នោត ១នាក់។ ក្នុងករណីអ្នកសុំចំឈ្មោះច្រើនបន្តជួរជាប់គ្នា នោះរយៈពេលនៃការចុះឈ្មោះនឹងថយតិចជាង ៥នាទីសម្រាប់អ្នកចុះឈ្មោះម្នាក់។

៣. ឧបករណ៍ជាមួយសំភារៈ កុំព្យូទ័រ និងកម្មវិធី (Software) ឧបករណ៍ក្នុងការប្រើប្រាស់សាកល្បង មានដំណើរការដោយរលូន ដោយមិនមានបញ្ហារអាក់រអួល ឬរាំងស្ទះនោះទេ។

៤. ច្រើនជាង ៩៩% នៃអ្នកចុះឈ្មោះមិនមានឈ្មោះស្ទួន ឬទិន្នន័យស្ទួនទេ ដោយប្រើប្រាស់ប្រព័ន្ធមិនភ្ជាប់សេវាអ៊ីនធឺណិត(Offline/Online)។ ក្នុងចំណោម ៦៥២នាក់ ដែលបានចុះឈ្មោះមាន ២ករណី ដែលកើតមានគឺ ករណីទី១ ជាអ្នកចុះឈ្មោះគួរកត់សម្គាល់ (the Registered Red Voter) បានបញ្ចូលឈ្មោះដល់ ២ដង បញ្ហានេះដោយសារតែស្នាមក្រយៅមេដៃរបស់យុវនារីម្នាក់ មានស្នាមក្រយៅដៃ ២នៅលើម្រាមតែមួយ រីឯករណីទី២ គឺមានអ្នកចុះឈ្មោះត្រូវការផ្តិតស្នាមក្រយៅដៃច្រើនដង ពីព្រោះអ្នកទាំងនោះ មានស្នាមក្រយៅដៃដែលសឹក ឬមានដំបៅ។

៥. ថវិកាប្រតិបត្តិការ ទាក់ទងទៅនឹងឧបករណ៍ សំភារៈ និងការផ្គត់ផ្គង់សម្រាប់សមាជិកក្រុមការងារនៃការចុះឈ្មោះ ត្រូវបានអនុវត្តតាមផែនការ។

រហូតមកដល់ឆ្នាំ២០១៦ គ.ជ.ប ថ្មីបានសម្រេចចិត្តសហការជាមួយអ្នកជំនាញការជប៉ុន និងអ្នកជំនាញការសហគមន៍អ៊ឺរ៉ុប រៀបចំបង្កើតប្រព័ន្ធចុះឈ្មោះបោះឆ្នោតថ្មី ស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័ន គ.ជ.ប និងរៀបចំចុះឈ្មោះដោយក្រុមចុះឈ្មោះបោះឆ្នោត។ ក្រុមការងារចុះឈ្មោះបោះឆ្នោតសរុបមានចំនួន ១៦៣៣ក្រុម ( មួយឃុំ សង្កាត់ មានចំនួនមួយក្រុម) ដែលហៅកាត់ថា ក.ច.ប ហើយក្រុមនិមួយៗ មានសមាជិកចំនួន ៣នាក់ ទៅ ៧នាក់ ក្នុងនោះមានប្រធាន ក.ច.ប (រើសដោយ គ.ជ.ប) អនុប្រធាន(ស្មៀនឃុំសង្កាត់ក្នុងមូលដ្ឋាន) និងមន្រ្តីការីកុំព្យូទ័រ ពី១នាក់ ទៅ ៤នាក់ រើសដោយ គ.ជ.ប ដោយយោងទៅលើចំនួនអ្នកមានសិទ្ធិចុះឈ្មោះតិចឬច្រើនក្នុងឃុំសង្កាត់។ គ.ជ.ប បានស្នើសុំរដ្ឋសភាជាតិសម្រេចផ្តល់ថវិកា ចំនួន ២៣លានដុល្លារ ក្នុងការរៀបចំដំណើរការចុះឈ្មោះបោះឆ្នោត ខណៈដែលសហគមន៍អ៊ឺរ៉ុបទទួលខុសត្រូវសម្ភារៈចុះឈ្មោះបោះឆ្នោតដូចជាកុំព្យូទ័រ និងប្រទេសជប៉ុនទទួលខុសត្រូវជួយផ្តល់ថវិកាសម្រាប់រៀបចំសម្ភារៈផ្ទុកទិន្នន័យ ( Server)។

## ១.៤ ផែនការ និងសកម្មភាពតាមកាលវិភាគរបស់ គ.ជ.ប

គ.ជ.ប បានសម្រេចរៀបចំចុះឈ្មោះបោះឆ្នោតថ្មីសម្រាប់ប្រជាពលរដ្ឋដែលមានអាយុគ្រប់បោះឆ្នោត គិតដល់ថ្ងៃបោះឆ្នោតចំនួនជាង ៩.៦លាននាក់នៅទូទាំង ២៥រាជធានីខេត្ត រយៈ ៩០ថ្ងៃ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ដល់ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៦។ ការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការជារៀងរាល់ថ្ងៃគិតទាំងថ្ងៃសៅរ៍ និងអាទិត្យ ពេលព្រឹក ចាប់ពីម៉ោង ៧:០០ ដល់ ១១:៣០ និងពេលរសៀលចាប់ពីម៉ោង ២:០០ ដល់ ៥:៣០។ នៅក្នុងផែនការជាដំបូង គ.ជ.ប បានចេញសេចក្តីប្រកាសរបស់ខ្លួនក្នុងការចុះឈ្មោះបោះឆ្នោត ដែលចាប់ផ្តើម នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ប៉ុន្តែត្រូវបានពន្យាពេលដោយសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត ព្រោះមានភាពយឺតយ៉ាវ ដែលសម្ភារៈនេះជាជំនួយផ្តល់ដោយសហគមន៍អ៊ឺរ៉ុប។

រយៈពេលចុងក្រោយនៃថ្ងៃរៀបចំការចុះឈ្មោះនេះ ខុមហ្វ្រែល ក៏ដូចជាសង្គមស៊ីវិលផ្សេងទៀត បានសង្កេតឃើញថា ប្រជាពលរដ្ឋមានចំនួនច្រើនបានសម្រុកមកចុះឈ្មោះបោះឆ្នោតខុសពីថ្ងៃធម្មតា។ ករណីនេះត្រូវបានសង្គមស៊ីវិល និងគណបក្សនយោបាយ សរសេរលិខិតស្នើសុំធ្វើការបន្ថែមពេលនៃការចុះឈ្មោះបន្ថែមទៀត ដើម្បីឲ្យប្រជាពលរដ្ឋមានលទ្ធភាពមកចុះឈ្មោះបន្ថែម។ ទន្ទឹមនឹងនេះផងដែរ គ.ជ.ប បានសម្រេចបន្ថែមថ្ងៃចុះឈ្មោះរយៈពេលមួយថ្ងៃបន្ថែមទៀតគឺរហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយយោងលើកិច្ចការផ្សេងៗ ដែលត្រូវធ្វើបន្ត និងកាលវិភាគបានកំណត់ទុក។

បញ្ជីឈ្មោះបោះឆ្នោតដំបូង ត្រូវបានបិទផ្សាយក្នុងឃុំ សង្កាត់នៅទូទាំងប្រទេសនៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៧។ រយៈពេលចាប់ពីការចុះឈ្មោះរហូតដល់ចេញបញ្ជីឈ្មោះដំបូងនេះ គឺអ្នកស្ម័គ្រចិត្តនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត របស់ គ.ជ.ប និងធ្វើការផ្ទៀងផ្ទាត់ម្តងទៀតនូវកំហុសឆ្គងទាំងឡាយនៃការបញ្ចូលព័ត៌មាន ដោយត្រួតពិនិត្យទិន្នន័យឡើងវិញទាំងអស់(១០០%) ដើម្បីមើលនូវបញ្ហាដែលអាចកើតមាន ដូចជាឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ និងទិន្នន័យផ្សេងៗទៀត។ បន្ទាប់ពីការកែតម្រូវ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត យកអ្វីដែលបានរកឃើញ ដាក់ជូនទៅគណកម្មការបច្ចេកទេសតំណាងឱ្យ គ.ជ.ប ដើម្បីសុំការសម្រេចមុនធ្វើការកែតម្រូវ ទើបបានលទ្ធផលជាបញ្ជីឈ្មោះបោះឆ្នោតដំបូងផ្ញើទៅឃុំ សង្កាត់។ ក្នុងរយៈពេលនៃការចេញនេះក៏មានបន្ទនីតិវិធីនៃបណ្តឹងផងដែរ មានដូចជាបណ្តឹងតវ៉ា និងការបដិសេធនៃការសុំចុះឈ្មោះបោះឆ្នោត ការដោះស្រាយ និងបដិសេធបណ្តឹង ទៅក្រុមប្រឹក្សាឃុំ សង្កាត់ ទៅ គ.ជ.ប និងទៅក្រុមប្រឹក្សាធម្មនុញ្ញផងដែរ។ ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីឈ្មោះបោះឆ្នោតផ្លូវការត្រូវបានចេញជាផ្លូវការនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៧។ ក្នុងរយៈពេលចេញបញ្ជីឈ្មោះដំបូងរហូតដល់បញ្ជីឈ្មោះបោះឆ្នោតផ្លូវការ ក៏មានការដាក់ និងដោះស្រាយនូវបណ្តឹងតវ៉ា និងបណ្តឹងជំទាស់លើបញ្ជីឈ្មោះបោះឆ្នោតផងដែរ។

## ១.៥ ក្រុមការងារចុះឈ្មោះបោះឆ្នោត (ក.ច.ប)

គ.ជ.ប បានធ្វើការព្យាកយណ៍អ្នកមានសិទ្ធិបោះឆ្នោត សម្រាប់បោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ នេះមានចំនួន ៩.៦៦៤.២១៦នាក់។ សម្រាប់ការចុះឈ្មោះនេះ គ.ជ.ប បានរៀបចំការចុះឈ្មោះក្នុង ១៦៣៣ឃុំ សង្កាត់ ដែលត្រូវការកុំព្យូទ័រចំនួន ២៤០០សម្រាប់។ ក្នុងដំណើរការចុះឈ្មោះ គ.ជ.ប ត្រូវការមន្ត្រីចុះឈ្មោះចំនួន ៧០២៧នាក់ ដែលក្នុងមួយឃុំសង្កាត់ ត្រូវមួយក្រុម ហើយក្នុងមួយក្រុមមានសមាសភាព ៣នាក់ ឬអាចលើសពីនេះតាមចំនួនអ្នកមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់និមួយៗ។



## ១.៦ ថវិកាក្នុងការចុះឈ្មោះបោះឆ្នោតថ្មីរបស់ គ.ជ.ប

គ.ជ.ប មានគម្រោងចំណាយថវិកាសម្រាប់ការចុះឈ្មោះបោះឆ្នោតជាមួយប្រជាពលរដ្ឋជាង ៩.៦លាននាក់ ដោយប្រើប្រាស់ថវិកាអស់ទឹកប្រាក់ ២៣លានដុល្លារសហរដ្ឋអាមេរិក។ ក្នុងការចំណាយទឹកប្រាក់ដែលត្រូវការនោះ គ.ជ.ប បានទទួលថវិកាពីម្ចាស់ជំនួយ ដូចជា សហគមន៍អឺរ៉ុប(EU) ចំនួន ៧.១លានដុល្លារ ពីប្រទេសជប៉ុន ចំនួន ១.១លានដុល្លារ ក្រៅពីនោះជាទឹកប្រាក់ដែលទទួលខុសត្រូវដោយរដ្ឋាភិបាល ចំនួន ១៤.៨ដុល្លារ។

**ថវិកា សរុប ២៣លានដុល្លារ**




## ១.៧ រចនាសម្ព័ន្ធក្នុងការគ្រប់គ្រងទិន្នន័យ និងកែតម្រូវ

ការចុះឈ្មោះបោះឆ្នោតត្រូវបានចុះនៅក្នុងទីតាំង ១៦៣៣ឃុំ សង្កាត់ ក្នុង២៥រាជធានីខេត្ត។ ដំណើរការក្នុងការចុះឈ្មោះគឺប្រើប្រាស់ដោយប្រព័ន្ធកុំព្យូទ័ររួមជាមួយការប្រើប្រាស់ជីវមាត្រ (Biometric) ដែលមានសម្ថភាពប្រើប្រាស់ដោយកម្មវិធីបិទ ឬបើក(Online/Offline មានន័យថាមិនមានភ្ជាប់សេវាអ៊ីនធឺណិតក៏បាន)។ ក្រុមការងារចុះឈ្មោះបោះឆ្នោតត្រូវបញ្ចូលព័ត៌មាននៅក្នុងឃុំ សង្កាត់ របស់ខ្លួននិងបញ្ជូនមកនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោតឆ្នោត និងបញ្ជីបោះឆ្នោត។ កន្លែងផ្ទុកទិន្នន័យ(Server)របស់ គ.ជ.ប បានរក្សាទិន្នន័យទាំងអស់ដែលបានផ្ញើមកពីទីកន្លែងចុះឈ្មោះបោះឆ្នោតទូទាំងប្រទេស។

ទិន្នន័យនៅឯកុំព្យូទ័រចុះឈ្មោះបោះឆ្នោតឃុំ សង្កាត់ ជារៀងរាល់ពេលនៃការឈប់សំរាក ក្រុមការងារចុះឈ្មោះត្រូវបានបង្កើតនូវលេខកូដកញ្ចប់ឃុំ សង្កាត់(Hash code) ដែលលេខកូដបានបង្ហាញពីភាពត្រឹមត្រូវរបស់ទិន្នន័យ និងធានាថាម៉ាស៊ីន ឬទិន្នន័យបានពីការចុះឈ្មោះបោះឆ្នោតមិនមាននរណាម្នាក់ចូលកែប្រែ។

ក្រោយពីទិន្នន័យបានផ្ញើមកដល់កន្លែងផ្ទុក(Server)របស់ គ.ជ.ប នៃនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត នោះក្រុមការងារនៅនាយកដ្ឋាន ធ្វើការត្រួតផ្ទៀតផ្ទាត់ទិន្នន័យ ដែលក្រុមការងារនេះចែកចេញជា ៣ក្រុម និងមានសិទ្ធិប្រើប្រាស់លើកម្មវិធីតាមមុខងារផ្សេងៗគ្នា ដូចខាងក្រោម៖

- ក្រុមការងារត្រួតពិនិត្យទិន្នន័យផ្ញើពីឃុំ សង្កាត់(ដោយកំណត់ទិន្នន័យខុសឬត្រូវ) ក្រុមនេះមិនមានលទ្ធភាពកែ ឬលុបទិន្នន័យឡើយ មានលទ្ធភាពកំណត់សម្គាល់តែប៉ុណ្ណោះ
- ក្រុមការងារលុបទិន្នន័យ ក្រុមនេះមានសិទ្ធិតែលុបទិន្នន័យដែលគណកម្មការបច្ចេកទេស (តំណាង គ.ជ.ប) បានសំរេចតែប៉ុណ្ណោះ
- ក្រុមការងារកែតម្រូវ ក្រុមនេះមើលឃើញតែទិន្នន័យដែលតម្រូវឱ្យកែប៉ុណ្ណោះ និងកែបានបន្ទាប់ពីគណកម្មការបច្ចេកទេសសម្រេច(តែងតាំងដោយសមាជិក គ.ជ.ប)។

**រូបភាពបង្ហាញពីដំណើរការនៃការបញ្ជូនទិន្នន័យ និងត្រួតពិនិត្យទិន្នន័យ**




## ១.៨ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

ការធ្វើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ ដោយឱ្យក្រសួងមហាផ្ទៃពន្លឿនការធ្វើ និងការចេញកាតនេះជូនប្រជាពលរដ្ឋ គិតមកដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៦ គ.ជ.ប បានប្រកាសស្ថិតិប៉ាន់ស្មាននៃចំនួនប្រជាពលរដ្ឋ ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើង មានចំនួន ១,៩៩១,០២៥នាក់ គ្មានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ក្នុងចំណោមប្រជាពលរដ្ឋ ៩,៦៦៤,២១៦នាក់ ដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតក្នុងការចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦នេះ។ ក្នុងការផលិតនៃ **អត្តសញ្ញាណបណ្ណ** ការសង្កេតឃើញថាគុណភាពមានបញ្ហាដោយការប្រើប្រាស់មិនទាន់បានរយៈពេលប៉ុន្មានផងបានរហែកខូច ប៉ុន្តែករណីនេះក្រសួងមហាផ្ទៃក៏បានចេញលិខិតជាសាធារណៈដើម្បីធ្វើជូនជាថ្មីដោយមិនគិតថ្លៃ។

ដោយហេតុថាអត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរគឺជាឯកសារគោលដ៏មានសារៈសំខាន់បំផុតសំរាប់ប្រជាពលរដ្ឋប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត និងយកទៅបោះឆ្នោតនាពេលខាងមុខ ព្រមទាំងឆ្លើយតបលើការមន្ទិលសង្ស័យ ខុមហ្វ្រែល និងសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត ក៏បានដាក់លិខិតទៅក្រសួងមហាផ្ទៃផងដែរ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ស្ដីពី «សុំការអនុញ្ញាតិផ្ដល់កិច្ចសហប្រតិបត្តិការ សិក្សាចង់ដឹង និងស្វែងយល់អំពីព័ត៌មានទាក់ទងទៅនឹងការចេញ ការ

ទទួលបាន ឬការមិនបានទទួលអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ» ដោយធ្វើការសិក្សានៅក្នុងឃុំសង្កាត់ ចំនួន៤គឺៈ រាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តរតនៈគីរី និងខេត្តបន្ទាយមានជ័យ ប៉ុន្តែមកដល់ពេលនេះ មិនមានការឆ្លើយតបណាមួយចំពោះលិខិតស្នើសុំនោះទេ។

**រូបភាពពីបង្ហាញពីគុណភាពនៃអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ**



រូបភាពពីហ្វេសប៊ុក

## ២. សង្ខេបក្របខណ្ឌច្បាប់ទាក់ទងការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦

ក្របខណ្ឌច្បាប់សម្រាប់ការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត ត្រូវបានរៀបចំថ្មី តាមរយៈការធ្វើវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។ ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦នេះ គឺប្រើប្រាស់ប្រព័ន្ធចុះឈ្មោះតាមបែបទំនើបជាលើកដំបូងសម្រាប់ប្រទេសកម្ពុជា។

### ២.១ ការផ្លាស់ប្តូរសំខាន់ៗ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងអំពីការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោតតាមបែបទំនើបនេះ។ ការផ្លាស់ប្តូរសំខាន់ៗ ចំនួន៧ចំណុចនៃប្បញ្ញត្តិនៅក្នុងច្បាប់ថ្មី ធៀបនឹងប្បញ្ញត្តិនៅក្នុងច្បាប់ចាស់ឃើញថាមានភាពវិជ្ជមាន។ ចំណុចផ្លាស់ប្តូរជាវិជ្ជមាន ទាំងនោះរួមមានៈ

១. **ទិន្នន័យអ្នកបោះឆ្នោតសម្រាប់បញ្ជីឈ្មោះបោះឆ្នោត** បញ្ញត្តិនៅក្នុងច្បាប់ថ្មីបានបន្ថែមការដៅសម្គាល់អត្តសញ្ញាណដែលមានតែមួយគត់សម្រាប់អ្នកបោះឆ្នោតម្នាក់ៗដូចជាៈ រូបថត និងស្នាមម្រាមដៃជាដើម។

២. **រយៈពេលនៃការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត** មានការផ្លាស់ប្តូរពេលវេលា (មកចុងរដូវប្រាំង) និងបង្កើនចំនួនថ្ងៃចុះឈ្មោះបោះឆ្នោតរហូតដល់ ៥០ថ្ងៃនៅឆ្នាំដែលមានការបោះឆ្នោត។

៣. **លក្ខខណ្ឌទីលំនៅសម្រាប់ការចុះឈ្មោះបោះឆ្នោត** បានបើកទូលាយឲ្យប្រជាពលរដ្ឋដែលមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់អាចចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នោះបាន។

៤. **ក្រុមចុះឈ្មោះបោះឆ្នោត** (ក.ច.ប) បញ្ញត្តិនៅក្នុងច្បាប់ថ្មីបានកំណត់ឲ្យ គ.ជ.ប ត្រូវចាត់តាំង ក.ច.ប សម្រាប់ឃុំ សង្កាត់នីមួយៗ ដើម្បីជួយគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវក្នុងការចុះឈ្មោះបោះឆ្នោត។

៥. **ព័ត៌មានអំពីការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត និងលក្ខខណ្ឌសម្រាប់អ្នកមានសិទ្ធិបោះឆ្នោត** ត្រូវធ្វើឡើងដោយស្មៀនឃុំ សង្កាត់ ខណៈដែលពួកគេត្រូវរាយការណ៍ទៅលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត រៀងរាល់ ០២ (ពីរ) ខែម្តង។

៦. **ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ចុះឈ្មោះបោះឆ្នោត** បានកំណត់យកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាឯកសារគោលប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត និងអនុញ្ញាតឲ្យប្រើតែលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការចុះឈ្មោះបោះឆ្នោតសម្រាប់អ្នកគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

៧. **ប្រព័ន្ធផ្ទុកទិន្នន័យបញ្ជីឈ្មោះអ្នកបោះឆ្នោត** បញ្ញត្តិនៅក្នុងច្បាប់ថ្មីបានកំណត់ឲ្យ គ.ជ.ប ត្រូវបង្កើតប្រព័ន្ធទិន្នន័យកុំព្យូទ័រសម្រាប់បញ្ជីឈ្មោះបោះឆ្នោត។

## ២.២ អនុសាសន៍ដែលបានផ្តល់ជូនដោយខុមហ្វ្រែល និងសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត

ដោយឡែកបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ ឃើញថាមានភាពវិជ្ជមានច្រើន ស្របទៅនឹងការផ្លាស់ប្តូរនៃបញ្ញត្តិ នៅក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្មី។ ទន្ទឹមគ្នានេះក៏មានចំណុចគួរកែលម្អមួយចំនួន ដូចជា ១) នីតិវិធីក្នុងការផ្ទៀងផ្ទាត់របស់ក្រុមចុះឈ្មោះបោះឆ្នោត និងអ្នកសុំចុះឈ្មោះបោះឆ្នោត ២) នីតិវិធីនៃការចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ៣) ការណែនាំ ឬនីតិវិធីក្នុងការផ្តិតស្នាមម្រាមដៃ និងការថតរូបអ្នកស្នើសុំចុះឈ្មោះបោះឆ្នោត ៤) សម្ភារៈ និងឧបករណ៍ចុះឈ្មោះបោះឆ្នោត ដែល គ.ជ.ប គួរតែបន្ថែមម៉ាស៊ីនព្រីនធ័រដើម្បីបោះពុម្ពបង្កាន់ដៃ ៥) ពង្រឹងសមត្ថភាពមន្ត្រីចុះឈ្មោះបោះឆ្នោត និង ៦) ធានាសិទ្ធិអ្នកបោះឆ្នោត ពិសេសពលករចំណាកស្រុកទៅក្រៅប្រទេស និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត។

ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦។ ក.ច.ប ចុះឈ្មោះជូនប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត តាមប្រព័ន្ធកុំព្យូទ័រ និងបញ្ជូនទិន្នន័យតាមប្រព័ន្ធអ៊ីនធឺណិតមក គ.ជ.ប ជាប្រចាំថ្ងៃ។ ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវមានទីតាំងនៅសាលាឃុំ សង្កាត់ ហើយការិយាល័យចុះឈ្មោះបោះឆ្នោតផ្សេងទៀតត្រូវមានទីតាំងនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់។ ការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការជារៀងរាល់ថ្ងៃគិតទាំងថ្ងៃសៅរ៍ និងអាទិត្យ ពេលព្រឹកចាប់ពីម៉ោង ៧:០០ ដល់ ១១:៣០ និងពេលរសៀលចាប់ពីម៉ោង ២:០០ ដល់ ៥:៣០។

អ្នកសុំចុះឈ្មោះបោះឆ្នោតម្នាក់ៗត្រូវឆ្លងកាត់ជំហានសំខាន់ៗចំនួន៣ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ទី១. ជួបប្រធានក្រុមចុះឈ្មោះ ដើម្បីសាកសួរអំពីឯកសារបញ្ជាក់អត្តសញ្ញាណ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ និងពិនិត្យ និងសម្រេចភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះ, ទី២. អនុប្រធានក្រុមបំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងទី៣. ការីកុំព្យូទ័រ កត់ត្រាទិន្នន័យអ្នកសុំចុះឈ្មោះទៅក្នុងប្រព័ន្ធកុំព្យូទ័រ ថតរូប និងផ្តិតស្នាមម្រាមដៃអ្នកសុំចុះឈ្មោះបោះឆ្នោតជាដើម។

ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌដូចជា មានសញ្ជាតិខ្មែរ មានអាយុដប់ប្រាំបី (១៨)ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត (ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧) មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត និងមានឯកសារបញ្ជាក់អត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការចុះឈ្មោះបោះឆ្នោត)។

### ២.៣ ក្របខណ្ឌនៃបទបញ្ញត្តិនៃច្បាប់ពាក់ព័ន្ធនឹងការដោះស្រាយបណ្ដឹងទាក់ទងនឹងការបទផ្សាយបញ្ជីដំបូង

#### ២.៣.១. សិទ្ធិ និងលក្ខខណ្ឌ នៃការចុះឈ្មោះបោះឆ្នោត

មាត្រា១២ នៃច្បាប់ស្ដីការបោះឆ្នោតឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់កថាខណ្ឌទី៣ចែងថា ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវទៅបោះឆ្នោត
- ពុំមែនជាជនវិកលចរិក ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច

មាត្រាដដែលនេះ បានបញ្ជាក់បន្ថែមក្នុងកថាខណ្ឌ បន្ទាប់អំពីការយកបទបញ្ញត្តិនៃមាត្រាមួយចំនួនក្នុងច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ យកមកអនុវត្តមានជាអាទិ៍បែបបទ និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីឈ្មោះបោះឆ្នោត លើកលែងតែមាត្រា៤៧ ចេញ។

មាត្រា៤៦ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានចែងអំពីលក្ខខណ្ឌដើម្បីអាចចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដូចបញ្ញត្តិនៃមាត្រា១២ នៃច្បាប់បោះឆ្នោតឃុំសង្កាត់ដែរ។

#### ២.៣.២. ភាពមានសិទ្ធិប្ដឹង និងសិទ្ធិទទួលបានការដោះស្រាយបណ្ដឹង លើការបិទផ្សាយបញ្ជីឈ្មោះបោះឆ្នោតបឋម

មាត្រា៦១ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចែងថា ក្នុងរយៈពេល០៥ (ប្រាំ) ថ្ងៃយ៉ាងយូរបន្ទាប់ពីបិទផ្សាយបញ្ជីឈ្មោះបោះឆ្នោតដំបូងជនណាក៏ដោយ ក៏អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួនពីការបាត់បង់ឈ្មោះ ឬជំទាស់ការចុះឈ្មោះ ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃជនណាម្នាក់ដែលខ្លួនមានភស្តុតាងបញ្ជាក់ថា៖

- ជននោះពុំមានលក្ខខណ្ឌត្រឹមត្រូវគ្រប់គ្រាន់តាមមាត្រ៤៦ និងមាត្រា៥១នៃច្បាប់នេះ។
- ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង។
- ជននោះបានមកចុះឈ្មោះមានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែជននោះគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ជននោះត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលុបឈ្មោះមិនត្រឹមត្រូវ។
- ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោត តែកត់ត្រាមិនច្បាស់លាស់។

អ្នកប្ដឹងតវ៉ាត្រូវបង្ហាញភស្តុតាងជាឯកសារណាមួយ ទៅក្រុមប្រឹក្សាឃុំ សង្កាត់។ អ្នកប្ដឹងជំទាស់ត្រូវផ្ដល់ព័ត៌មានបន្ថែម ក្នុងករណីមានការស្នើសុំពីក្រុមប្រឹក្សាឃុំ សង្កាត់។[1]

#### ២.៣.៣. ប្រភេទនៃសវនាការលើបណ្ដឹងបោះឆ្នោត

នៅក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ គ.ជ.ប គឺមានចែងអំពីប្រភេទ ឬនីតិវិធីនៃសវនាការដោះស្រាយបណ្ដឹងបោះឆ្នោតទាំងបីថ្នាក់ (១) ថ្នាក់ក្រុមប្រឹក្សាឃុំ សង្កាត់

[1] មានចែងបញ្ជាក់បន្ថែមនៅក្នុងបទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ ក្នុងប្រការ៥.៣.១, និងប្រការ ៥.៣.២។

(២) ថ្នាក់ គ.ជ.ប និង (៣) ថ្នាក់ក្រុមប្រឹក្សាធម្មនុញ្ញ បានកំណត់អោយស្ថានប័នដោះស្រាយវិវាទបោះឆ្នោតទាំងបីនេះត្រូវតែដោះស្រាយបណ្ដឹងតាមរយៈការបើកសវនាការជាសាធារណៈ។ ទោះជាយ៉ាងណាក្ដី គ្មានមាត្រា ឬបញ្ញត្តិណាមួយក្នុងច្បាប់ទាំងពីរនេះចែងអំពីប្រភេទសវនាការទាំងបី ស្ដីពីនីតិវិធីជំនុំជម្រះ និងនីតិវិធីសវនាការ (សវនាការសង្ខេប សវនាការតទល់ និងសវនាការសួរដេញដោល) ឡើយ វាលែងតែក្នុងបទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ ត្រង់ប្រការ ៥.៣.២០ និងប្រការ ៥.១៥.១ ប៉ុន្តែទោះជាយ៉ាងណាក្ដីបទបញ្ជា និងនីតិវិធីត្រូវចែងអោយស្របជាមួយនឹងច្បាប់ស្ដីការបោះឆ្នោត និងច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប តាមឋានាក្រម ដែលមានជាធរមាន។ បើទោះជាអវត្តមានភាសាឬខ្លឹមសារនៃប្រភេទ ឬនីតិវិធីសវនាការក្នុងច្បាប់បោះឆ្នោតបែបនេះក្ដី សម្រាប់ការនីតិវិធីជំនុំជម្រះ និងការអនុវត្តនីវិធីសវនការនីមួយៗ ដូចដែលមានចែងក្នុងប្រការ ៥.១៥ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបឡឆ្នោត គ.ជ.ប ត្រូវអនុវត្តទៅការបញ្ញត្តិនៃច្បាប់ដែលតម្រូវអោយបើកធ្វើជាសាធារណៈ។

មាត្រា៦២ នៃច្បាប់ដដែលនេះ តម្រូវអោយក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រជុំសម្រេចលើបណ្ដឹងតវ៉ា និងជំទាស់ជាសាធារណៈ ក្នុងរយៈពេល ០៣ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង។[2] កថាខណ្ឌទី៤ នៃមាត្រានេះចែងថា បន្ទាប់ពីទទួលបានពាក្យបណ្ដឹងទាស់នឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវសម្រេចលើបណ្ដឹងតវ៉ា ឬជំទាស់ ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ០៥ថ្ងៃយ៉ាងយូរ។[3]

មាត្រា៦៣ នៃច្បាប់នេះដដែល មានចែងអំពីសមត្ថកិច្ច និងនីតិវិធីសវនាការនៃក្រុមប្រឹក្សាធម្មនុញ្ញ ដោយចែងថា បន្ទាប់ពីទទួលពាក្យបណ្ដឹង ដែលប្ដឹងទាស់នឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្ដឹងតវ៉ា ឬជំទាស់នោះដោយបើកសវនាការជាសាធារណៈ។[4]

មាត្រា៤២ កថាខណ្ឌទី២៥ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ចែងអំពីសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវទាក់ទងនឹងផែនការកម្ម ការរៀបចំ ការចាត់ចែង និងត្រួតពិនិត្យការបោះឆ្នោត៖ «សម្រេចដោយបើកសវនាការសាធារណៈលើបណ្ដឹងលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោត លើកលែងតែបណ្ដឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ»។

[2] មានចែងបញ្ជាក់បន្ថែមនៅក្នុងបទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ ក្នុងប្រការ ៥.៣.៣ ដល់ប្រការ ៥.៣.១១។

[3] មានចែងបញ្ជាក់បន្ថែមនៅក្នុងបទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ ក្នុងប្រការ ៥.៣.១២ ដល់ប្រការ ៥.៣.២៣។

[4] មានចែងបញ្ជាក់បន្ថែមនៅក្នុងបទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ ក្នុងប្រការ ៥.៣.២៤ ដល់ប្រការ ៥.៣.២៩។

# ក. របាយការណ៍សង្កេតទូទៅអំពីដំណើរការចុះឈ្មោះបោះឆ្នោត

## ក.១. ការជ្រើសរើសមន្ត្រីសម្រាប់ការចុះឈ្មោះបោះឆ្នោត

### ក.១.១. ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាសម្រាប់បម្រើការងារចុះឈ្មោះបោះឆ្នោតនៅលេខាធិការដ្ឋានរាជធានី ខេត្ត រៀបចំការបោះឆ្នោត (លធ.ខប)

ការសង្កេតឃើញថា គណៈកម្មការជ្រើសរើសមានសមាសភាពចូលរួមស្របតាមសេចក្ដីសម្រេចរបស់ គ.ជ.ប។ រីឯការផ្សព្វផ្សាយគឺធ្វើឡើងស្របតាមសេចក្តីជូនដំណឹងរបស់ គ.ជ.ប ដោយមានការបិទផ្សាយនៅស្នាក់ការ លធ.ខប និងតាមទីប្រជុំជន ក្រុង ស្រុក ខណ្ឌ និងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយក្នុងរាជធានី/ខេត្ត។ លើសពីនេះ ការសង្កេតឃើញថា ខេត្តមួយចំនួនបានបន្ថែមការផ្សព្វផ្សាយតាមឧឃោសនស័ព្ទ ឬតាមប្រព័ន្ធផ្សព្វផ្សាយសង្គម (Facebook) ដូចជា ខេត្តកណ្ដាល និងខេត្តពោធិសាត់ជាដើម។

ឆ្លងតាមដំណើរការនៃការរៀបចំក្របខណ្ឌជ្រើសរើស (សេចក្ដីសម្រេច និងគោលការណ៍ណែនាំ) និងដំណើរការនៃការជ្រើសរើសតាមរាជធានី ខេត្ត យើងអាចធ្វើការវាយតម្លៃបានថា ការរៀបចំក្របខណ្ឌច្បាប់បានល្អ ដោយមានកំណត់ពីគោលការណ៍ការចូលរួម របស់សមាជិក គ.ជ.ប ដែលបានចុះទៅដល់ខេត្ត។ ជាមួយគ្នានេះ ការផ្សព្វផ្សាយសេចក្តីសម្រេច និងគោលការណ៍ណែនាំទាំងនោះក៏ប្រព្រឹត្តទៅបានល្អអាចទទួលយកបាន។ ប៉ុន្តែទន្ទឹមនឹងនេះ ការសង្កេតក៏រកឃើញនូវចំណុចខ្វះខាតមួយចំនួនដូចជា អ្នកទទួលព័ត៌មានពីការផ្សព្វផ្សាយនៅមានកម្រិត ការលំបាកខ្លះៗក្នុងការស្វែងរកបេក្ខជនដែលមានជំនាញលើមុខតំណែងមួយចំនួន កម្រិតនៃការចូលរួមពីបេក្ខជនជាស្ត្រីជាដើម។

គ.ជ.ប បានប្រកាសជ្រើសរើសមន្ត្រី បុគ្គលិកជាប់កិច្ចសន្យា រយៈពេលខ្លី ចំនួន**៧៤១នាក់** រួមទាំងគ្រូបង្ហាត់ ចាប់ពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ ដល់ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីបម្រើការងារនៅ លធ.ខប សម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ដែលក្នុងរាជធានី ខេត្តនីមួយៗ ។

នៅក្នុងការជ្រើសរើស គ.ជ.ប បានធ្វើសេចក្ដីជូនដំណឹងកំណត់អំពីលក្ខខណ្ឌសម្រាប់ជ្រើសរើសបេក្ខជន និងលក្ខខណ្ឌដោយឡែកសម្រាប់មុខជំនាញនីមួយៗ ព្រមទាំងកំណត់អំពីរយៈពេលធ្វើការប្រាក់កម្រៃដែលត្រូវទទួលបាន។

### ក.១.២. ការជ្រើសរើសក្រុមចុះឈ្មោះក្រុមចុះឈ្មោះបោះឆ្នោត តាមឃុំ សង្កាត់

គ.ជ.ប បានប្រកាសជ្រើសរើសមន្ត្រី ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ចំនួន**១,៦៣៣ក្រុម** ស្មើនឹងចំនួន **៦,១០៣ នាក់** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាមឃុំ សង្កាត់ទូទាំងប្រទេសចាប់ពីថ្ងៃទី២៣ ខែសីហា ដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ សម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ដែលមានតំណែងដូចជា ១.ប្រធាន ក.ច.ប, ២.សមាជិក ក.ច.ប ជាជំនួយការអនុប្រធាន និង៣. សមាជិក ក.ច.ប ជាការីកុំព្យូទ័រ។

យោងតាមបទបញ្ញា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត គ.ជ.ប បានតែងតាំងគណៈកម្មការជ្រើសរើសមួយនៅថ្នាក់ជាតិ ដោយមានប្រធាន ឬ អនុប្រធាន លធ.ខប គ្រប់រាជធានី ខេត្តជាសមាជិក។ ការសង្កេតឃើញថា គណៈកម្មការ និងអនុគណៈកម្មការជ្រើសរើសមានសមាសភាពចូលរួមស្របតាមបទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប។ តែទោះជាការផ្សព្វផ្សាយអំពីដំណឹងជ្រើសរើសមានធ្វើតាមរយៈតែការបិទផ្សាយនៅសាលាឃុំ/សង្កាត់ និងនៅទីស្នាក់ការលេខាធិការដ្ឋានរាជធានី/ខេត្តរៀបចំការបោះឆ្នោតប៉ុណ្ណោះ ដែលធ្វើឲ្យដំណឹងអំពីការជ្រើសរើសមិនបានផ្សព្វផ្សាយដោយទូលំទូលាយដល់សាធារណជនទូទៅនោះទេ។ អ្នកដែលទទួលបានព័ត៌មានភាគច្រើន គឺជាមន្ត្រីដែលធ្លាប់បម្រើការងារនៅគណៈកម្មការរៀបចំការបោះឆ្នោតក្នុងការបោះឆ្នោតកន្លងមក និងជាមន្ត្រីរាជការ។

នៅក្នុងដំណើរការជ្រើសរើស ការសង្កេតឃើញថា បេក្ខជនដែលបានដាក់ពាក្យក្នុងតំណែងប្រធាន គ.ច.ប ភាគច្រើន គឺមន្ត្រីធ្លាប់បម្រើការងាររៀបចំការបោះឆ្នោតក្នុងការបោះឆ្នោតកន្លងមក។ ដោយឡែក បេក្ខជនក្នុងតំណែងការីកុំព្យូទ័រ ភាគច្រើនគឺជាបេក្ខភាពថ្មី និងជាយុវជន។

អនុគណៈកម្មការជ្រើសរើសបានជួបការលំបាក ពិសេសក្នុងការស្វែងបេក្ខជនសម្រាប់តំណែងការីកុំព្យូទ័រដែលមានសមត្ថភាព នៅក្នុងឃុំមួយចំនួនក្នុងខេត្តមណ្ឌលគិរី ខេត្តសៀមរាប ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តត្បូងឃ្មុំ ខេត្តកោះកុង ខេត្តស្ទឹងត្រែង និងខេត្តរតនៈគិរី។ ឧទាហរណ៍ ជាក់ស្តែងនៅឃុំស្រែព្រះ ស្រុកកែវសីមា បេក្ខជនដែលសំរាំងយកសម្រាប់តំណែងការីកុំព្យូទ័រមានតែម្នាក់ ហើយសរុបពិន្ទុទាំងបី (សញ្ញាបត្រ បទពិសោធន៍ការបោះឆ្នោត និងពិន្ទុប្រឡង) បានតែ១៨/១០០ ត្រូវបានជ្រើសយក បើទោះបីជាពិន្ទុមិនជាប់មធ្យមភាគក៏ដោយ។ នៅក្នុងឃុំមេម៉ង ឃុំចុងផ្លាស់ ក្នុងស្រុកកែវសីមានេះដែរបេក្ខជនសំរាំងយកសម្រាប់តំណែងការីកុំព្យូទ័រក៏មានតែម្នាក់ ហើយសរុបពិន្ទុទាំងបីគឺសូន្យ ដែលធ្វើឲ្យគណៈកម្មការជ្រើសរើសមិនអាចជ្រើសរើសបានបេក្ខជននោះទេ។ (ទោះជាយ៉ាងណាគណៈកម្មការជ្រើសរើសបានដោះស្រាយបញ្ហានេះ។)

បញ្ហាបក្សពួកនិយមក្នុងការផ្តល់ព័ត៌មាន និងការសំរាំងយកបេក្ខជនក៏ត្រូវបានរាយការណ៍ថា កើតមានឡើងខ្លះៗផងដែរ ដូចជានៅសង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនៈគីរី និងនៅឃុំជយោ ស្រុក ចំការលើ ខេត្តកំពង់ចាមជាដើម។ ដោយឡែកនៅតាមឃុំ សង្កាត់មួយចំនួនមានជួបបញ្ហាអាក់រអួលនៅពេលបេក្ខជនធ្វើតេស្តកុំព្យូទ័រ តែទោះយ៉ាងណា វាមិនបានធ្វើឲ្យរាំងស្ទះដំណើរជ្រើសរើសនោះទេ។ បេក្ខជនដាក់ពាក្យ និងបេក្ខជនដែលត្រូវបានជ្រើសរើសជាស្ត្រីមានចំនួនតិចជាងបេក្ខជនជាបុរស។

ជាទូទៅដំណើរការជ្រើសរើស គ.ច.ប មានលក្ខណៈល្អប្រសើរជាងការជ្រើសរើសមន្ត្រីរៀបចំការបោះឆ្នោតកន្លងមក។ គណៈកម្មការជ្រើសរើស ឬអនុគណៈកម្មការអនុវត្តតាមលក្ខខណ្ឌដែលកំណត់ដោយបទបញ្ជា និងនីតិវិធីការធ្វើតេស្តមានតម្លាភាព គណៈកម្មការជ្រើសរើសមានសមាសភាពចូលរួមចម្រុះ។

### ក.២. ការបណ្តុះបណ្តាលមន្ត្រីចុះឈ្មោះបោះឆ្នោត

ក្នុងដំណាក់កាលបណ្តុះបណ្តាល គ.ជ.ប បានបណ្តុះបណ្តាលដល់ លធ/ខប មកពីគ្រប់រាជធានីខេត្ត និងមន្ត្រីរបស់ គ.ជ.ប ដែលមានទាំងនីតិវិធី និងបច្ចេកទេសក្នុងការប្រើប្រាស់កុំព្យូទ័រផងដែរ។ ក្នុងការអនុវត្តផ្ទាល់ក្នុងការប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធចុះឈ្មោះបោះឆ្នោត ព្រមទាំងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតក្នុងការបញ្ជូនទិន្នន័យមកមជ្ឈមណ្ឌលកុំព្យូទ័រ។

ការអនុវត្តន៍ និងការបង្ហាញនៅថ្នាក់ គ.ជ.ប គ្រូឧទ្ទេសនាមបានបង្ហាញ របៀបប្រើប្រាស់ របៀបបញ្ជូនទិន្នន័យ និងការប្រើប្រាស់លេខកូដកញ្ចប់សុវត្ថិភាពឃុំសង្កាត់ផងដែរ។ ការបង្រៀនតគ្នាពីថ្នាក់ គ.ជ.ប មក លធ/ខប និងពី លធ/ខប មកគ្រូបង្គោលថ្នាក់ស្រុក និងចុងក្រោយ គឺក្រុមចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំសង្កាត់។

ការសង្កេតឃើញថា ការបណ្តុះបណ្តាលបង្កើតការយល់ដឹង និងសមត្ថភាពដល់មន្ត្រីចុះឈ្មោះបោះឆ្នោតក្នុងដំណើរការប្រព័ន្ធចុះឈ្មោះបោះឆ្នោតថ្មីនេះ។ តែគ្រូបង្គោលថ្នាក់ស្រុក បានបណ្តុះបណ្តាលដល់ក្រុមចុះឈ្មោះបោះឆ្នោតមានការខ្វះខាតចំណុចសំខាន់មួយចំនួន ដូចជាការណែនាំលេខកូដកញ្ចប់សុវត្ថិភាពឃុំសង្កាត់(Hash Code) ដល់ក្រុមចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំសង្កាត់។

## គ.៣. ការរៀបចំការិយាល័យបោះឆ្នោត

ការសង្កេតការណ៍ឃើញថា មាន៣ការិយាល័យមួយចំនួនបានបង្កើតឡើងប្រើប្រាស់សម្រាប់តែប៉ូលិស និងទាហាន ដែលអាចត្រូវបកស្រាយជាបញ្ហាទាក់ទិននយោបាយក្នុងឃុំទាំងនោះ។ ដូចជាការិយាល័យ១០២៦ ដែលមាននៅក្នុងទីតាំងភូមិស្លាបក្តោង ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដែលប្រើប្រាស់សម្រាប់តែការចុះឈ្មោះឲ្យតែទាហានចំនួន៣០០(បីរយនាក់) ទោះបីទីនោះមានប្រជាពលរដ្ឋរស់នៅជាមួយក៏ដោយ។ បញ្ហានេះធ្វើឲ្យមានការជជែកគ្នារវាងក្រុមប្រឹក្សាឃុំសង្កាត់ដែលមកពីគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ រហូតមានការតវ៉ាគ្នា ក្រោយមកក៏មានការបើកឲ្យប្រជាពលរដ្ឋដែលរស់នៅទីនោះចូលរួមចុះឈ្មោះជាមួយវិញ គួរឲ្យកត់សម្គាល់ផងដែរថា ភូមិនេះកាលពីការបោះឆ្នោតឆ្នាំ២០១២ គណបក្សប្រជាជន ទទួលបានសម្លេង ៥១៦៣សម្លេង និងគណបក្សសង្គ្រោះជាតិទទួលបាន ៣១៦៦សម្លេង (សមរង្ស៊ី ១៥៦៣សម្លេង និងសិទ្ធិមនុស្ស ១៦០៣សម្លេង)។ តែលទ្ធផលការបោះឆ្នោតក្នុងឆ្នាំ២០១៣ គឺគណបក្សប្រជាជនទទួលបាន ៤១៨៤សម្លេង និងគណបក្សសង្គ្រោះជាតិទទួលបាន ៥៤២២សម្លេង។

ឧទាហរណ៍មួយទៀត នៅក្នុងខេត្តកំពង់ឆ្នាំង នៅភូមិថ្លុកឫស្សី ឃុំសេដ្ឋី មានការិយាល័យលេខ ០៧៨០ គឺត្រូវបានបំបែកចេញពីការិយាល័យ ០៦២៤ សំរាប់ទាហាន និងក្រុមគ្រួសារ និងប្រជាពលរដ្ឋមានចំនួនភាគតិច តែនៅក្នុងឃុំនេះមានការិយាល័យជាច្រើនទៀតមិនទាន់គ្រប់ចំនួនអ្នកចុះឈ្មោះនៅឡើយទេ ដូចជាការិយាល័យលេខ ០៦១៦, ០៦១៧, ០៦១៤, ០៦១៥, ០៦២៥ និង០៦២២ ដែលមានចម្ងាយក្រោម ២គីឡូម៉ែត្រពីបន្ទាយ និងមានប្រជាពលរដ្ឋគ្រប់ចុះឈ្មោះមិនលើសពី ៤០០នាក់ ក្នុងការិយាល័យនិមួយៗ។ ការស្នើសុំបង្កើតការិយាល័យនេះ ក្រោមហេតុផលពីស្មៀន និងក្រុមប្រឹក្សាឃុំសង្កាត់គ្រាន់តែបានបញ្ជាក់ថា មានទាហាន និងក្រុមគ្រួសាររបស់ពួកគេអាចចុះឈ្មោះច្រើន។ បើមើលនូវលទ្ធផលប្រកួតប្រជែងក្នុងការបោះឆ្នោតឆ្នាំ២០១៣ បង្ហាញថា សម្លេងគណបក្សទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា(មានសម្លេង ១៨៣១សម្លេង) និងគណបក្សសង្គ្រោះជាតិ(ទទួលបាន ១៨៤០សម្លេង) មានសម្លេងប្រកៀកគ្នា។

នៅក្នុងខេត្តកំពង់ឆ្នាំងនេះដដែលក៏មានការបង្កើតការិយាល័យថ្មីមួយទៀតលេខ ០៧៨១ គឺជាការស្នើសុំរបស់ក្រុមប្រឹក្សាឃុំ ដែលបានដាក់សំណើតាំងពីមុនការចុះឈ្មោះបោះឆ្នោតមកម្ល៉េះ តែ គ.ជ.ប មិនបានផ្តល់អោយ លុះដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ទើបមានការអនុញ្ញាតជាផ្លូវការនៅក្នុងកុំព្យូទ័រ។ តាមការបញ្ជាក់ពីមេឃុំ ការបង្កើតការិយាល័យថ្មីនេះ ដោយសារតែមានភូមិទើបបង្កើតថ្មី គឺភូមិក្តុលអភិវឌ្ឍន៍នៅដាច់ឆ្ងាយពីភូមិផ្សេងៗ និងការិយាល័យបោះឆ្នោតចាស់ដែលស្ថិតនៅក្នុងឃុំស្វាយជុកប្រហែល ២៧គីឡូម៉ែត្រ ហើយការិយាល័យនេះនៅជាប់តំបន់ដែលមានកងកម្លាំងរាជអាវុធហត្ថ និងក្រុមគ្រួសាររស់នៅ តែទោះជាយ៉ាងណា តាមការសង្កេតការិយាល័យថ្មីនេះមានប្រជាពលរដ្ឋចំនួន ១២៤នាក់ និងទាហានចំនួន ៤២០នាក់ (តាមលិខិតស្នើសុំរបស់មេឃុំក្នុងឧបសម្ព័ន្ធចំណុច១)។ លទ្ធផលនៃឃុំស្វាយជុកនេះ មិនខុសពីលទ្ធផលនៃឃុំសេដ្ឋីនោះទេ បើមើលលទ្ធផលនៃការប្រកួតប្រជែងវិញសង្កេតឃើញថា លទ្ធផលនៃការបោះឆ្នោតឆ្នាំ២០១៣ លទ្ធផលនៃគណបក្សទាំងពីរ គឺប្រកៀកប្រកិតគ្នា ដោយគណបក្សប្រជាជនទទួលបាន ១៨៧២សម្លេង និងគណបក្សសង្គ្រោះជាតិទទួលបាន ២០១៤សម្លេង។

## ក.៤. ការចេញលិខិតបញ្ជាក់ទីលំនៅ ឬឯកសារបញ្ជាក់អត្តសញ្ញាណជូនកងកម្លាំងប្រដាប់អាវុធ

មានលិខិតអំពីការចេញឯកសារជូននគរបាលជាតិ ឬយោធិន ដែលទៅចុះឈ្មោះបោះឆ្នោត ដោយ ប្រធាន គ.ជ.ប តាមរយៈលិខិតលេខ ១០៣១/១៦ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ណែនាំ ៣(បី) ចំណុច (សូមមើលលិខិត ក្នុងឧបសម្ព័ន្ធ ត្រង់ចំណុចទី៤)។ បើពិនិត្យក្របខ័ណ្ឌច្បាប់នេះ ចំណុចទី២ និងទី៣ នៃលិខិតមិនអាចត្រូវបានបកស្រាយថា ទីកន្លែងនៃផែនការ «បេសកកម្ម» គឺស្មើនឹង «ទីសំណាក់» ដែលកំពុងរស់នៅក្នុងឃុំសង្កាត់ ដូចមានចែងក្នុងចំណុច ៤.៤.៧ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦។ នគរបាលជាតិ ឬយោធិន ឬសន្តិសុខបោះឆ្នោត បំពេញបេសកកម្មរយៈពេលយូររហូតដល់ថ្ងៃបោះឆ្នោតក្នុងឃុំ សង្កាត់ និងកម្លាំងសន្តិសុខបោះឆ្នោត ដែលត្រូវមានបេសកកម្មការពារសន្តិសុខនៅថ្ងៃបោះឆ្នោត នៅតាមការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិសុំលិខិតបញ្ជាក់ទីលំនៅសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការចុះឈ្មោះបោះឆ្នោត គឺមិនស្របតាមខ្លឹមមាត្រា៤៦ ស្តីពីលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត និងមាត្រា៤៧ ស្តីពីលក្ខខណ្ឌលើកលែងក្នុងការចុះឈ្មោះបោះឆ្នោត ក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនោះទេ។ ការបកស្រាយ និងលិខិតរបស់ គ.ជ.ប នេះ មានគោលបំណងដើម្បីបង្កើតវិធានការពិសេសជាវិជ្ជមាន ក្នុងការលើកស្ទួយសិទ្ធិបោះឆ្នោតរបស់នគរបាលជាតិ ឬយោធិន ឬសន្តិសុខបោះឆ្នោតទាំងនោះ។

ក្នុងករណីអនុវត្តលិខិត គ.ជ.ប ខាងលើ ដើម្បីធានាសិទ្ធិបោះឆ្នោតរបស់នគរបាលជាតិ ឬយោធិន ឬសន្តិសុខបោះឆ្នោត ខុមហ្វ្រែលស្នើថា គ.ជ.ប ត្រូវអនុវត្តឲ្យមានតម្លាភាព និងបង្ហាញចំនួនកម្លាំងសន្តិសុខ និងទីតាំងដែលពួកគេត្រូវបំពេញបេសកកម្មក្រៅពីឃុំ សង្កាត់រស់នៅ និងក៏មិនត្រូវបង្កើតការិយាល័យបោះឆ្នោតដោយឡែកសម្រាប់តែនគរបាលជាតិ ឬយោធិន ឬសន្តិសុខបោះឆ្នោតដែលឈរជើង ឬបំពេញបេសកកម្មទាំងនោះទេ។

ការសង្កេតរកឃើញ ១៦ឃុំដែលអនុវត្តការបញ្ជាក់លិខិតទីលំនៅ ឬឯកសារបញ្ជាក់អត្តសញ្ញាណដល់កងកម្លាំងប្រដាប់អាវុធ។

នៅក្នុងខេត្តព្រះវិហារ ស្រុកគូលេន ក្នុងឃុំស្រយង់ បានយកទាហានជាច្រើនទៅចុះឈ្មោះ និងប្រាប់ឲ្យលោកមេឃុំចេញលិខិតបញ្ជាក់ទីលំនៅជូនទាហានសម្រាប់ការចុះឈ្មោះបោះឆ្នោត។ ករណីនេះត្រូវបានលោកមេឃុំបដិសេធមិនធ្វើជូនចំពោះនាយទាហានណាដែលលោកស្គាល់ថា មិនឈរជើង ឬរស់នៅទីនោះ តែលោកបានចេញជូនចំពោះតែនាយទាហានណាដែលលោកស្គាល់ និងដឹងថា បានរស់នៅក្នុងដីសម្បទានសង្គមកិច្ចតែប៉ុណ្ណោះ។ ការបដិសេធនេះបានធ្វើឲ្យមានការមិនសប្បាយចិត្ត និងគម្រាមកំហែងថា នឹងប្តឹងមេឃុំទៀតផង រហូតមានការប្រតិកម្មពីមេឃុំ និងក៏មានការចេញលិខិតអន្តរាគមន៍ផងដែរពី គ.ជ.ប ចុះថ្ងៃទី ២៤ខែតុលា ឆ្នាំ២០១៦ ទៅក្រសួងមហាផ្ទៃធ្វើជូនចំពោះសម្តេចក្រឡាហោមឲ្យចាត់វិធានការ និងអន្តរាគមន៍។ ការកត់សម្គាល់នៅក្នុងនេះបានបង្ហាញថា គណបក្សប្រជាជនទទួលបានលទ្ធផលឆ្នោតចំនួន ១២៥៨សម្លេង និងគណបក្សសង្គ្រោះជាតិចំនួន ១០០៧សម្លេង ក្នុងការបោះឆ្នោតឆ្នាំ២០១៣។

នៅក្នុងខេត្តសៀមរាប មានឃុំចំនួនពីរ គឺឃុំតាសៀម ស្រុកស្វាយលើ និងឃុំត្បែង ស្រុកបន្ទាយស្រី ដែលមានទាហានមកចុះឈ្មោះបោះឆ្នោតដែលគេមិនបានដឹងថា គាត់រស់នៅទីនោះច្បាស់លាស់ ហើយបានឲ្យមេឃុំបញ្ជាក់ទី

លំនៅជូន។ ករណីនេះ មេឃុំតាសៀមបានប្រតិកម្ម តវ៉ានិងធ្វើការផ្អាកក្នុងការចេញលិខិតនេះផងដែរ។ បញ្ហានេះក៏មានការស៊ើបអង្កេត និងចេញលិខិតអន្តរាគមន៍ពី គ.ជ.ប ផងដែរ (សូមមើលលិខិតយោងក្នុងឧប្បសម្ព័ន្ធត្រង់ចំណុច៣)។ ការកត់សម្គាល់បានបង្ហាញថា ក្នុងឃុំត្បែង ស្រុកបន្ទាយស្រី គណបក្សប្រជាជនទទួលបានលទ្ធផលឆ្នោតចំនួន ២៥១៩សម្លេង និងគណបក្សសង្គ្រោះជាតិចំនួន ១១៥៤សម្លេង ក្នុងការបោះឆ្នោតឆ្នាំ២០១៣ រីឯឃុំតាសៀម ស្រុកស្វាយលើ គណបក្សប្រជាជនទទួលបានលទ្ធផលឆ្នោតចំនួន ១៦៥៧សម្លេង និងគណបក្សសង្គ្រោះជាតិចំនួន ៩២៥សម្លេង ក្នុងការបោះឆ្នោតឆ្នាំ២០១៣។

នៅខេត្តបន្ទាយមានជ័យ អ្នកសង្កេតការណ៍បានសង្កេតឃើញនូវដំណើរការចុះឈ្មោះបោះឆ្នោត នៅតាម ស្រុកមង្គលបូរី និង សង្កាត់នៅក្រុងសិរីសោភ័ណ មានប៉ូលិស ទាហាន ប៉េអឹមបានចល័តពង្រាយចុះឈ្មោះបោះឆ្នោត ១៣ឃុំ នៅស្រុកមង្គលបូរី ខេត្តបន្ទាយមាន ដោយពួកគាត់បានចុះឈ្មោះបោះឆ្នោតនៅកន្លែងផ្សេងរួចមកហើយ តែពួកគាត់មកចុះ តាមឃុំនៅស្រុកមង្គលបូរី ដោយបានយកកន្ទុយប័ណ្ណដែលចុះពីមុនភ្ជាប់ជាមួយ មកចុះកន្លែងថ្មី ។ ទាក់ទងចំណុចមិនប្រក្រតីខាងលើនេះ ប្រធានគណកម្មការរៀបចំការបោះឆ្នោតខេត្ត បានបង្ហាញថា ហេតុផលគឺសំរាប់អោយពួកគាត់ការពារសន្តិសុខនៅកន្លែងនោះ ដោយសារស្រុកនោះខ្វះសមត្ថកិច្ចការពារសន្តិសុខតាមការិយាល័យនៅពេលបោះឆ្នោត។ សមត្ថកិច្ចទាំងនោះត្រូវបានវាយឈ្មោះតាមក្រដាសដាក់ទៅតាមឃុំនីមួយៗ ដើម្បីអោយអាជ្ញាធរដែនដីទទួលស្គាល់ និងចុះឈ្មោះបោះឆ្នោតពួកគាត់នៅទីនោះ ហើយលុបឈ្មោះគាត់ចេញពីបញ្ជីដែលបានចុះរួចហើយវិញ។ ក្នុងករណីនេះ នៅក្នុងឃុំដែលនៅក្នុងស្រុកមង្គលបុរី ឃើញថាលទ្ធផលគឺគណបក្សប្រជាជនទទួលបានលទ្ធផលឆ្នោតសម្លេងច្រើនជាង គណបក្សសង្គ្រោះជាតិ ច្រើនជាង ៤៦.៤២%សម្លេង ក្នុងការបោះឆ្នោតឆ្នាំ២០១៣។ សម្រាប់ឃុំសង្កាត់ទាំងឡាយដែលមាននៅក្នុងក្រុងសិរីសោភ័ណ សម្គាល់ឃើញថាសម្លេងរបស់គណបក្សប្រជាជនទទួលបានលទ្ធផលឆ្នោត សម្លេងច្រើនជាង គណបក្សសង្គ្រោះជាតិ ច្រើនជាង ៣៥.៨៣%សម្លេង ក្នុងការបោះឆ្នោតឆ្នាំ២០១៣។

## ក.៥. ប្រជាពលរដ្ឋចំណាកស្រុករស់នៅក្រៅប្រទេស

នៅចុងបញ្ចប់នៃការចុះឈ្មោះបោះឆ្នោត គ.ជ.ប បានប្រកាសថា ប្រជាពលរដ្ឋមិនបានមកចុះឈ្មោះគ្រប់ចំនួនតាមផែនការនោះទេ បញ្ហានេះគឺដោយសារតែជនចាស់ជរា ឈឺ និងមានប្រជាពលរដ្ឋទៅចំណាកស្រុកជាង ១លាននាក់ទៅធ្វើការ និងរស់នៅក្រៅប្រទេសដែលមិនអាចវិលត្រឡប់មកចុះឈ្មោះបោះឆ្នោតវិញបាន។

សម្រាប់ប្រជាពលរដ្ឋដែលចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសភាគច្រើន មិនបានចុះឈ្មោះបោះឆ្នោតនៅឃុំសង្កាត់របស់ពួកគេ ព្រោះថា គ្មានលទ្ធភាព សោហ៊ុយ ពេលវេលា និងឯកសារបញ្ជាក់អត្តសញ្ញាណ និងទីលំនៅ ឧទាហរណ៍ ជាក់ស្តែងកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ពលករចំណាកស្រុកធ្វើការនៅប្រទេសថៃប្រមាណជាង ៨០ នាក់ ក្នុងនោះមានពលករមានលិខិតឆ្លងដែន និងពលករមានប័ណ្ណពណ៌ស៊ីជម្ពូ(ប័ណ្ណចេញនិងទទួលស្គាល់ដោយភាគីថៃ)។ ពលករដែលមានលិខិតឆ្លងដែន មិនមានបញ្ហានោះទេ តែពលករដែលមានប័ណ្ណស៊ីជម្ពូ តម្រូវឲ្យបង់ថវិកាចេញចូលចំនួន៦០០បាត ដែលនាំឲ្យពួកគាត់មិនមានលទ្ធភាពក្នុងការបង់ថ្លៃសេវាដល់អាជ្ញាធរថៃនៅច្រកទ្វារព្រំដែន។ បញ្ហាទាំងនេះតម្រូវឲ្យមានការអន្តរាគមន៍ពីអាជ្ញាធរខ្មែរ ដើម្បីសម្រួលដល់ពលករអ្នកមានប័ណ្ណពណ៌ស៊ីជម្ពូដើម្បីកុំឲ្យត្រូវ

ចំណាយប្រាក់ក្នុងការបង់ថ្លៃចេញចូល តែការអន្តរាគមន៍ត្រូវបានយឺតយ៉ាវ។ ទាក់ទងប្រជាពលរដ្ឋចំណាកស្រុកនេះផង ដែរ ខាងគណបក្សសង្គ្រោះជាតិបានដាក់លិខិតឲ្យជួយអន្តរគមន៍ ហើយក៏ទទួលការឆ្លើយតបពី គ.ជ.ប វិញដែរ គឺ គ.ជ.ប តបទៅវិញថាមិនមានលទ្ធភាព និងសមត្ថកិច្ចដោះស្រាយនោះទេ(សូមមើលលិខិតឧបសម្ព័ន្ធ ចំណុចទី៦)។

## ក.៦. អំពីព្រះសង្ឃ

ទាក់ទងជាមួយព្រះសង្ឃ ការសង្កេតឃើញថា ព្រះសង្ឃនិមន្តមកចុះឈ្មោះមានចំនួនតិចតួចណាស់ បើប្រៀបធៀបជាមួយចំនួនព្រះសង្ឃសរុបទូទាំងប្រទេសប្រហែល៥ម៉ឺនអង្គ (យោងតាមព័ត៌មានរបស់វិទ្យុអាស៊ីសេរី ព្រះសង្ឃតែជាង ៨ពាន់៨រយអង្គ តែប៉ុណ្ណោះ ដែលបាននិមន្តទៅចុះឈ្មោះបោះឆ្នោតក្នុងឃុំសង្កាត់)។ បញ្ហាដែលមិនសូវមានសង្ឃទៅចុះឈ្មោះបោះឆ្នោតច្រើននេះ ខុមហ្វ្រែលបានសង្កេតឃើញថា គឺអាចបណ្តាលមកពីការហាមប្រាមរបស់មន្ត្រីសង្ឃជាន់ខ្ពស់ដោយសារតែមានសង្ឃប្រកាសចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលហាមឃាត់ព្រះសង្ឃមិនឲ្យជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ ព្រមទាំងមិនទាន់លុបចោលនូវឡើយ។ ម្យ៉ាងទៀតព្រះសង្ឃព្រះអង្គមិនមានអត្តសញ្ញាណប័ណ្ណ ដែលជាឯកសារចម្បងបម្រើឲ្យការចុះឈ្មោះបោះឆ្នោតផង។

បណ្តាញព្រះសង្ឃឯករាជ្យព្រះតេជគុណ ប៊ុត ប៊ុនតិញ ដែលជាប្រធានបណ្តាញព្រះសង្ឃឯករាជ្យ មានសង្ឃដីកាថា ព្រះអង្គបានធ្វើការសិក្សាស្រាវជ្រាវលើខេត្តចំនួន៤ គឺខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប ព្រះអង្គបានប៉ាន់ប្រមាណថា មានចំនួនតិចតួច។

ព្រះសង្ឃដែលគ្រប់អាយុចុះឈ្មោះបោះឆ្នោត ហើយមិនបាននិមន្តទៅចុះឈ្មោះបោះឆ្នោត គឺដោយសារតែ ទី១ មិនបានធ្វើសំបុត្រកំណើត ព្រោះបួសមុនការធ្វើ ហើយអាជ្ញាធរមិនបានជួយសម្រួល ទី២ អាជ្ញាធរមិនព្រមធ្វើលិខិតបញ្ជាក់អត្តសញ្ញាណ ទាល់តែសក្សីជាសមាជិកគណបក្សទើបជួយសម្រួលឱ្យ ទី៣ គឺកត្តាកង្វះខាតព័ត៌មាន ទី៤ ការរារាំងពីអាជ្ញាធរភូមិឃុំ ក្នុងខេត្តមួយចំនួន ដូចជានៅខេត្តពោធិ៍សាត់ អាជ្ញាធរនិយាយបង្អើលព្រះសង្ឃថា អត្តសញ្ញាណបណ្ណមិនអាចទៅចុះឈ្មោះបានទេ និងទី៥ គឺមិនបានយកចិត្តទុកដាក់ទៅលើការបោះឆ្នោតដោយព្រះកាយព្រះសង្ឃខ្លួនឯងផ្ទាល់តែម្តង។

## ក.៧. ការអប់រំ និងផ្សព្វផ្សាយព័ត៌មានចុះឈ្មោះបោះឆ្នោត

### ក.៧.១ ភាគីពាក់ព័ន្ធអង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ

នៅក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ ត្រង់ជំពូក២ ក្នុងប្រការ ២.១.៤.១១ និងប្រការ ២.១.៥ គ.ជ.ប ធ្វើការទំនាក់ទំនង និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងផ្តល់ការគាំទ្រដល់ភាគីពាក់ព័ន្ធដើម្បីអប់រំអ្នកបោះឆ្នោត លើកកម្ពស់ការយល់ដឹងអំពីការបោះឆ្នោត ដើម្បីជំរុញការងារអប់រំសាធារណជនឲ្យបានទូលំទូលាយដល់ជនបទដាច់ស្រយាល។

ការអប់រំឯកសារផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោតត្រូវបានរារាំងដោយអាជ្ញាធរ និងមិនបានអន្តរាគមន៍ឲ្យមានប្រសិទ្ធភាពពីស្ថាប័ គ.ជ.ប ជាក់ស្តែងការផ្សព្វផ្សាយមួយចំនួន ត្រូវបានមើលឃើញពីការរារាំងដោយអាជ្ញាធរមានសមត្ថកិច្ចមូលដ្ឋាន ចំពោះគណបក្សនយោបាយ និងសង្គមស៊ីវិល។

ច្បាប់ទាក់ទិនសមត្ថកិច្ចរបស់ គ.ជ.ប ត្រូវធានាឲ្យដំណើរការចុះឈ្មោះបោះឆ្នោតដោយសុវត្ថិភាព ហើយអាជ្ញាធរត្រូវតែផ្តល់កិច្ចសហការជាមួយ គ.ជ.ប ប៉ុន្តែ គ.ជ.ប បានចេញលិខិតលេខ ៨៦៤/១៦ គ.ជ.ប (មើលក្នុងឧបសម្ព័ន្ធចំណុច៥) ឲ្យគណបក្សសង្គ្រោះជាតិ ទៅសុំការអនុញ្ញាតពីអាជ្ញាធរ ដើម្បីបានការពារសុវត្ថិភាពក្នុងការងារអប់រំទៅវិញ។

ករណីនេះទាក់ទងអាជ្ញាធរហាមឃាត់ការអប់រំ សង្កេតឃើញកើតមាននៅក្នុងខេត្តមួយចំនួនដូចខាងក្រោម៖

- ខេត្តបាត់ដំបង ស្រុកឯកភ្នំ ឃុំសំរោងក្នុង ក្នុងភូមិសំរោងអូទ្រា ដែលបានចូលរួមអប់រំប្រជាពលរដ្ឋដោយចាក់ផ្សាយទាំងស្រុងពីសារសម្លេងដើមរបស់ គ.ជ.ប តាមម៉ូតូជូនដល់ប្រជាពលរដ្ឋ តែត្រូវបានហាមឃាត់ការចាក់ផ្សាយពីអាជ្ញាធរ និងហៅឲ្យទៅកាន់អធិការដ្ឋានស្រុក។ និងករណីនៅក្នុងសង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ក៏មានការហាមឃាត់ការចាក់ផ្សាយសារអប់រំពីសកម្មជនគណបក្សសង្គ្រោះជាតិផងដែរ ដោយមូលហេតុថា ការស្នើសុំគឺមានតែរយៈពេល ៣ថ្ងៃ តែការចាក់ផ្សាយនេះលើសពី ៣ ថ្ងៃ ហេតុនេះអាជ្ញាធរឃុំបានហាមឃាត់មិនឲ្យចាក់បន្តផ្សាយបន្តទៀតនោះទេ។
- ខេត្តសៀមរាប នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ អាជ្ញាធរស្រុកក្រឡាញ់ បានហាមឃាត់ការចាក់ផ្សាយតាមមេក្រូនូវសារដើមរបស់ គ.ជ.ប ពីសកម្មជនរបស់គណបក្សសង្គ្រោះជាតិ ដោយហេតុផលថាមិនបានសុំច្បាប់អនុញ្ញាតទុកជាមុន។

**រូបភាពហាមឃាត់ការចាក់ផ្សាយពីអាជ្ញាធរមានសមត្ថកិច្ច**



រូបភាពពីហ្វេសប៊ុក

- សមាគមអាដហុក មានកម្មវិធីអប់រំដល់ប្រជាពលរដ្ឋនៅតាមខេត្ត តែមានករណីខេត្តពីរ គឺខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល ត្រូវបានអាជ្ញាធរមិនចូលរួមសហការ ទោះបីមានលិខិតចេញពី គ.ជ.ប ក្នុងកិច្ចសហប្រតិបត្តិការរវាងសង្គមស៊ីវិល និង គ.ជ.ប ក៏ដោយ។ បញ្ហានេះសមាគមអាដហុកបានដាក់លិខិតជូនដល់សាលាខេត្ត តែសាលាខេត្តមិនអនុញ្ញាតឲ្យធ្វើទេ ដោយតម្រូវឲ្យមានលិខិតអនុញ្ញាតពីក្រសួង

មហាផ្ទៃជាមុន(សូមមើលលិខិតក្នុងឧបសម្ព័ន្ធត្រង់ចំណុច២)។ ចំណែកឯខេត្តផ្សេងទៀតដែលយល់ព្រម និងសហការជាមួយសមាគមនអាដហុក ធ្វើសកម្មភាពចុះផ្សាយពីសិទ្ធិអ្នកបោះឆ្នោតក៏ដោយ ក៏នូវតែមានការរារាំង និងឃ្លាំមើលពីសំណាក់អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចមួយចំនួននូវឡើយ តែទោះជាយ៉ាងណាបុគ្គលិកសមាគមន៍អាដហុកព្យាយាមសម្របសម្រួលរហូតបានបើកវគ្គផ្សព្វផ្សាយតាមដំណើរការផែនការ។ ករណីទាំងនេះកើតមាននៅខេត្តបន្ទាយមានជ័យ ខេត្តព្រះវិហារ និងខេត្តរតនៈគិរី។

- ករណីនៅភ្នំពេញ ក្នុងពិធីបុណ្យអុំទូក មានយុវជនចំនួន ៥០នាក់ ដែលមកពីអង្គការសង្គមស៊ីវិល ក្នុងសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតហៅកាត់ថា ERA បានចូលរួមផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោតនេះផងដែរ តាមរយៈចែកខិតបណ្ណ កូនសៀវភៅ និងមេក្រូផងដែរ។ ក្នុងពេលដែលបានប្រើប្រាស់មេក្រូផ្សព្វផ្សាយព័ត៌មានក្នុងពិធីនោះក៏ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចហាមឃាត់ការចាក់មេក្រូនេះ។



រូបភាពខុមហ្វ្រេល

ករណីឲ្យជួយអន្តរាគមន៍ក្នុងការអប់រំនេះ ត្រូវបាន គ.ជ.ប ចេញលិខិតឲ្យភាគីពាក់ព័ន្ធត្រូវសុំការអនុញ្ញាតពីអាជ្ញាធរពាក់ព័ន្ធដើម្បីរក្សាសន្តិសុខសុវត្ថិភាព រីឯឯកឧត្តមប្រធានក៏មានប្រសាសន៍នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្នុងកិច្ចប្រជុំរវាងគណកម្មការជាតិរៀបចំការបោះឆ្នោត និងសង្គមស៊ីវិល មានចំណុចដូចគ្នា និងលិខិតដែលបានចេញពីមុនផងដែរ ដោយសំអាងលើការថែរក្សាសន្តិសុខសាធារណៈ។

## ក.៧.២. គ.ជ.ប និងអាជ្ញាធរឃុំសង្កាត់

មានការផ្សព្វផ្សាយរបស់ គ.ជ.ប តាមរយៈវិទ្យុ ទូរទស្សន៍ ការលើកបដាគ្រប់ឃុំសង្កាត់ និងមានការចាក់មេក្រូផ្សាយតាមឃុំសង្កាត់នៅខែទី១ នៃដំណើរការចុះឈ្មោះបោះឆ្នោត។

គ.ជ.ប ក៏បានចេញលិខិតអញ្ជើញទៅចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ជូនដល់ប្រជាពលរដ្ឋសម្រាប់មកចុះឈ្មោះបោះឆ្នោតនៅតាមឃុំសង្កាត់ផងដែរ ចំនួន ១០លានសន្លឹក។ ការសង្កេតឃើញថា លិខិតនេះ គឺមិនមែនជាលិខិតអញ្ជើញទេ តែវាគ្រាន់តែជាប័ណ្ណព័ត៌មានអំពីការចុះឈ្មោះបោះឆ្នោត ព្រោះថាលិខិតនេះគ្មានបញ្ជាក់ថា ត្រូវតែទៅចុះឈ្មោះ ហើយការបែងចែកនេះមិនបានគ្រប់ចំនួនដល់ប្រជាពលរដ្ឋនោះទេ។

## រូបលិខិតអញ្ជើញរបស់ គ.ជ.ប ឲ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ដែលបានចែកជូនប្រជាពលរដ្ឋ



**លិខិតអញ្ជើញទៅចុះឈ្មោះបោះឆ្នោតឆ្នាំ ២០១៦**

ការចុះឈ្មោះបោះឆ្នោតចាប់ផ្ដើមពីថ្ងៃទី ០១ ខែ កញ្ញា ដល់ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

សូមអញ្ជើញប្រជាពលរដ្ឋទាំងអស់ ដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត (ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៧) និងមានលំនៅឋាន ឬទីសំណាក់នៅក្នុងឃុំ សង្កាត់ ទៅចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ឬនៅតាមភូមិមួយចំនួននៅក្នុងឃុំ សង្កាត់ដែលបងប្អូនកំពុងរស់នៅ តាមកាលវិភាគរបស់ក្រុមចុះឈ្មោះបោះឆ្នោត ។ **សូមយកទៅជាមួយនូវ ÷** អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

## គ.៨. ការទទួល និងការដោះស្រាយបណ្ដឹង

មិនមានភាពប្រក្រតីធ្ងន់ធ្ងរ និងបណ្ដឹងច្រើនទេក្នុងអំឡុងការសង្កេតដំណើរការចុះឈ្មោះបោះឆ្នោត តែភាពមិនប្រក្រតីកើតច្រើន ដែលគួរឲ្យយកចិត្តទុកដាក់នោះ គឺការបញ្ចូនទិន្នន័យខុស និងការមិនពិនិត្យ និងផ្ទៀងផ្ទាត់ឈ្មោះ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។ ក្រុមប្រឹក្សាឃុំសង្កាត់ក៏ខិតខំដោះស្រាយបណ្ដឹងបាន ៥០% ដែលមានការទទួលពាក្យបណ្ដឹង និងបដិសេធបណ្ដឹងមិនច្រើន។

### គ.៨.១. ការទទួល

ក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាឃុំសង្កាត់ (កបឃ.ស) និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានទទួល និងដោះស្រាយពាក្យបណ្ដឹង សរុបទូទាំងប្រទេសបានចំនួន ៩៧បណ្ដឹង ក្នុងនោះ បណ្ដឹងនៅថ្នាក់ ឃុំសង្កាត់(កបឃ.ស) បានទទួល និងដោះស្រាយពាក្យបណ្ដឹងសរុបចំនួន ៥២បណ្ដឹង គ.ជ.ប បានទទួលពាក្យបណ្ដឹង ចំនួន ៤៥បណ្ដឹង និងបណ្ដឹងនៅ គ.ជ.ប មាន ៤៥បណ្ដឹង។

ក្នុងការទទួលពាក្យបណ្ដឹងទាំងនៅថ្នាក់ឃុំ/សង្កាត់ និង នៅថ្នាក់ គ.ជ.ប នេះ ការសង្កេតឃើញ ភាគច្រើននៃបណ្ដឹង គឺពាក់ព័ន្ធនឹងអនុវត្តតួនាទី បំពេញតួនាទី របស់មន្ត្រីចុះឈ្មោះបោះឆ្នោត និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ដែលជាអ្នកមានសមត្ថកិច្ចចេញលិខិតបញ្ជាក់ទីលំនៅជូនអ្នកមកចុះឈ្មោះបោះឆ្នោត។

បណ្ដឹងនៅខេត្តព្រះវិហារ (ប្ដឹងគ្រូបង្គោល គ.ជ.ប ថ្នាក់ស្រុក ដែលបញ្ជាអោយក្រុមប្រឹក្សាឃុំ/សង្កាត់ចេញលិខិបញ្ជាក់ទីលំនៅដល់ពលរដ្ឋដែលគ្មានទីលំនៅក្នុងឃុំឆែបពីរ នៃស្រុកឆែប)។ ករណីនៅខេត្តកំពុងឆ្នាំង (ពាក់ព័ន្ធនឹងបណ្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់ កបឃ.ស (ការបង្កើតការិយាល័យបន្ថែមមួយការិយាល័យ សម្រាប់តែកងរាជអាវុធហត្ថ)។ បណ្ដឹងនៅរាជធានីភ្នំពេញ (ការបដិសេធមិនព្រមចេញលិខិតបញ្ជាក់ទីលំនៅជូនអ្នកមកចុះឈ្មោះមកបោះឆ្នោត ដែលមានអត្តសញ្ញាណប័ណ្ណនៅខេត្តកណ្ដាល ដែលមានសាក្សីមួយជាម្នាក់ហើយ, បណ្ដឹងតវ៉ា លើការមិនព្រមចុះឈ្មោះបោះឆ្នោតឲ្យ និងមិនបានណែនាំឲ្យទៅធ្វើលិខិតបញ្ជាក់ទីលំនៅដើម្បីយកមកចុះឈ្មោះ។ ករណីនៅព្រះវិហារ

(ប្តឹងគ្រូបង្គោល គ.ជ.ប ថ្នាក់ស្រុក ដែលបញ្ជាអោយក្រុមប្រឹក្សាឃុំ/សង្កាត់ចេញលិខិតបញ្ជាក់ទីលំនៅដល់ពលរដ្ឋដែលគ្មានទីលំនៅក្នុងឃុំឆែបពីរ នៃស្រុកឆែប)។ ករណីនៅសៀមរាប ( ប្តឹងចៅសង្កាត់រងទី១ នៃសង្កាត់ស្លក្រាម ដែលហាមឃាត់ភ្នាក់ងារគណបក្ស ស.គ.ជ មិនអោយធ្វើជាសាក្សីជូនប្រជាពលរដ្ឋដែលស្នើសុំលិខិតបញ្ជាក់ទីលំនៅ និងលិខិតបញ្ជាក់អត្តសញ្ញាណបំរើការចុះឈ្មោះបោះឆ្នោត(ឯ.អ)។

គណបក្សសង្គ្រោះជាតិបានដាក់ពាក្យបណ្តឹងច្រើនជាងគេនៅក្នុងដំណាក់កាលដោះស្រាយនៅថ្នាក់ កបឃ/ស គឺមានរហូតដល់ ៣៨បណ្តឹង, តាមពីក្រោយដោយគណបក្សបក្សប្រជាជនមាន ៧បណ្តឹង ប្រជាពលរដ្ឋមាន ៣បណ្តឹង គណបក្សសម រង្ស៊ី ២បណ្តឹង អាជ្ញាធរក្រុងស្រុកខណ្ឌ ១បណ្តឹង និងពីមន្ត្រី ក.ច.ប ចំនួន១បណ្តឹង។

### ក.៨.២. ដោះស្រាយបណ្តឹងនៅក្រុមប្រឹក្សាឃុំសង្កាត់(កបឃ.ស)

ដោះស្រាយនៅថ្នាក់ កបឃ/ស (ក្រុមប្រឹក្សាឃុំ/សង្កាត់) ក្នុងចំណោម ៥២បណ្តឹងដែលបានផ្សះផ្សាជាចំនួន២៥ បណ្តឹង, ចារបដិសេធ ៣បណ្តឹង ដើមបណ្តឹងដកពាក្យបណ្តឹង ៣បណ្តឹង ផ្សះផ្សាមិនសះជា ៨បណ្តឹង និងលិខិតជូនដំណឹងចំនួន ១៣បណ្តឹង។

សម្រាប់ស្ថិតិពាក់ព័ន្ធនឹងចុងចម្លើយដែលទទួលរងបណ្តឹងពីដើមបណ្តឹងខាងលើរួមមាន មន្ត្រី ក.ច.ប ចំនួន ២៣ បណ្តឹង, ប្រជាពលរដ្ឋ ១០បណ្តឹង, គណបក្សសង្គ្រោះជាតិ ៥បណ្តឹង គណបក្សប្រជាជនកម្ពុជា ២បណ្តឹង, នគរបាល ២ បណ្តឹង និងអាជ្ញាធរក្រុងស្រុកខណ្ឌ កបឃ.ស ជំទប់ទី១ ប្រធានភូមិ និងអនុប្រធានភូមិ សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ស្មៀន អនុប្រធានភូមិ និងជំនួយការសង្កាត់ គណបក្សសមរង្ស៊ី មួយបណ្តឹងដូចៗគ្នា (សរុប១០បណ្តឹង)។

ខេត្តដែលមានបណ្តឹង ហើយត្រូវទទួល និងដោះស្រាយនៅថ្នាក់ កបឃ.ស រួមមានៈ

- ខេត្តបាត់ដំបង ៣ បណ្តឹង
- ខេត្តកំពង់ឆ្នាំង ២បណ្តឹង (ផ្សះផ្សាសះជា១ និងលិខិតជូនដំណដឹង១)
- ខេត្តកំពត ៣បណ្តឹង (ផ្សះផ្សាសះជា ១បណ្តឹង, ដកពាក្យបណ្តឹង ១ និងចារបដិសេធ១)
- ខេត្តកណ្តាល ៣បណ្តឹង (ផ្សះផ្សាសះជា ២ និងលិខិតជូនដំណឹង១)
- ភ្នំពេញ ២០បណ្តឹង (ផ្សះផ្សាសះជា ៩ មិនសះជា ៣ ចារបដិសេធ២ និង លិខិតជូនដំណឹង៦)
- ខេត្តសៀមរាប ២០បណ្តឹង (ផ្សះផ្សាសះជា ១១ មិនសះជា ៥ ដកពាក្យបណ្តឹង២ និងលិខិតជូនដំណឹង ២) និងខេត្តព្រះសីហនុ ១បណ្តឹង (ផ្សះផ្សាសះជា)។

### ក.៨.២. ការដោះស្រាយបណ្តឹងនៅ គ.ជ.ប

បណ្តឹងដែលបាន និងកំពុងដោះស្រាយនៅថ្នាក់ គ.ជ.ប មាន ៤៥បណ្តឹង ប្តឹងដោយគណបក្សប្រជាជនកម្ពុជា, មាន ២២បណ្តឹង ប្តឹងដោយគណបក្សសង្គ្រោះជាតិមាន ៦បណ្តឹង ប្តឹងដោយគណបក្ស សម រង្ស៊ី មាន១បណ្តឹង ប្តឹងដោយគណបក្សសិទ្ធិមនុស្ស មាន៩បណ្តឹង ប្តឹងដោយប្រជាពលរដ្ឋមាន ១បណ្តឹង ប្តឹងដោយរដ្ឋបាលក្រុង និង១បណ្តឹង ប្តឹងដោយមេធាវីជាតំណាងកូនក្តី។ បណ្តឹងពាក់ព័ន្ធនឹងការបង្កការអុកឡុក រារាំងការចុះឈ្មោះបោះឆ្នោតមានចំនួន១៤បណ្តឹង និងពាក់ព័ន្ធនឹងការចេញលិខិតបញ្ជាក់ទីលំនៅមាន ១៤បណ្តឹងដូចគ្នា។

ខេត្តដែលមានបណ្តឹង ហើយត្រូវទទួល និងដោះស្រាយនៅថ្នាក់ គ.ជ.ប រួមមានៈ

- ខេត្តបាត់ដំបង (លិខិតជូនដំណឹង ២បណ្តឹង)
- ខេត្តកំពង់ឆ្នាំង (កំពុងដោះស្រាយ ១បណ្តឹង)
- ខេត្តកណ្តាល (ដើមបណ្តឹងដកពាក្យបណ្តឹង ១)
- រាជធានីភ្នំពេញ (មាន២៤បណ្តឹងក្នុងនោះ កំពុងដោះស្រាយ២បណ្តឹង លិខិតជូនដំណឹង១៨ ដកពាក្យបណ្តឹង១ និងចារបដិសេធ៣បណ្តឹង)
- ខេត្តព្រះវិហារ (លិខិតជូនដំណឹង ៤បណ្តឹង)
- ខេត្តព្រៃវែង (លិខិតជូនដំណឹង ១បណ្តឹង)
- ខេត្តសៀមរាប (១១បណ្តឹង ក្នុងនោះរួមមាន កំពុងដោះស្រាយ១បណ្តឹង លិខិតជូនដំណឹង ៩បណ្តឹង និងចារបដិសេធ១បណ្តឹង)
- និងខេត្តព្រះសីហនុ (លិខិតជូនដំណឹង ១បណ្តឹង)។

**តារាងសង្ខេបការនៃការដោះស្រាយនៅ គ.ជ.ប**

| ល.រ | ខេត្ត/រាជធានី | ប្រភេទបណ្តឹង | ចំនួន | ដំណោះស្រាយ |
|---|---|---|---|---|
| ១ | បាត់ដំបង | បណ្តឹងនាំអោយមានការដាក់ទោសពិន័យ/ផ្តន្ទាទោស | ២ | លិខិតជូនដំណឹង |
| ២ | កំពង់ឆ្នាំង | បណ្តឹងជំទាស់ | ១ | កំពុងដោះស្រាយ |
| ៣ | កណ្តាល | បណ្តឹងនាំឲ្យមានការដាក់ទោសពិន័យ/ផ្តន្ទាទោស | ១ | ដកពាក្យបណ្តឹង |
| ៤ | ភ្នំពេញ | បណ្តឹងតវ៉ា, បណ្តឹងនាំឲ្យមានការដាក់ទោសពិន័យ/ផ្តន្ទាទោស និងបណ្តឹងពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ។ | ២៤ | ចារបដិសេធ, លិខិតជូនដំណឹង និងកំពុងដោះស្រាយ |
| ៥ | ព្រះវិហារ | បណ្តឹងនាំឲ្យមានការដាក់ទោសពិន័យ/ផ្តន្ទាទោស និងបណ្តឹងពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ។ | ៤ | លិខិតជូនដំណឹង/កំពុងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ |
| ៦ | ព្រៃវែង | បណ្តឹងនាំអោយមានការដាក់ទោសពិន័យ/ផ្តន្ទាទោស | ១ | លិខិតជូនដំណឹង |
| ៧ | សៀមរាប | បណ្តឹងនាំឲ្យមានការដាក់ទោសពិន័យ/ផ្តន្ទាទោស និងបណ្តឹងពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ។ | ១១ | ចារបដិសេធ, លិខិតជូនដំណឹង, កំពុងដោះស្រាយ |
| ៨ | ព្រះសីហនុ | ជំទាស់, បណ្តឹងនាំអោយមានការដាក់ទោសពិន័យ/ផ្តន្ទាទោស | ១ | លិខិតជូនដំណឹង |
| ៩ | សរុប | បណ្តឹងជំទាស់, បណ្តឹងតវ៉ា និងបណ្តឹងនាំឲ្យមានការដាក់ទោសពិន័យ/ផ្តន្ទាទោស និងបណ្តឹងពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ។ | ៤៥ | ចារបដិសេធ ៤ (ដាក់ក្រោយអំឡុងពេលកំណត់), ដកពាក្យបណ្តឹង ២, លិខិជូនដំណឹង ៣៥ និងកំពុងដោះស្រាយ ៤ |

## ក.៩ ការដោះស្រាយបណ្តឹងទាក់ទងបញ្ជីឈ្មោះបោះឆ្នោតដំបូង

### ក.៩.១ ការដោះស្រាយបណ្តឹងនៅ គ.ជ.ប

ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ គឺជាថ្ងៃចាប់ផ្តើមនៃការដោះស្រាយពាក្យបណ្តឹងនៃការប្តឹងតវ៉ា និងប្តឹងជំទាស់ទៅនឹងការបិទផ្សាយបញ្ជីឈ្មោះបោះឆ្នោតដំបូង ដែលត្រូវបានបិទផ្សាយនៅតាមឃុំ/សង្កាត់ រយៈពេល១០ថ្ងៃ ដើម្បីផ្តល់ឱកាសអោយប្រជាពលរដ្ឋ ឬគណបក្សនយោបាយ ប្តឹងតវ៉ា និងប្តឹងជំទាស់ ទៅនឹងបញ្ជីឈ្មោះបោះឆ្នោតដំបូង។ ផ្អែកតាមបទបញ្ជា និងនីតិវិធី គ.ជ.ប មានពេលវេលារយៈពេល ០៥ ថ្ងៃសម្រាប់ដោះស្រាយបណ្តឹងទាំងនោះ មានន័យថា ការដោះស្រាយបណ្តឹងគឺចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២១៧។ សវនាការសាធារណៈ នៃបណ្តឹងពាក់ព័ន្ធនឹងការបិទបញ្ជីឈ្មោះបោះឆ្នោតបឋម ដែលត្រូវបានប្តឹងជំទាស់ និងតវ៉ាមកកាន់ គ.ជ.ប ជំទាស់ទៅការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានធ្វើឡើងត្រឹមតែរយៈពេលបីថ្ងៃប៉ុណ្ណោះ គឺចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៧។ ចាប់ពីថ្ងៃទី១៩ មក គ.ជ.ប បានប្តូរនីតិវិធីនៃសវនាការរបស់ខ្លួនទៅជាសវនការសង្ខេបវិញ។ តាមន័យដែលត្រូវបានបំភ្លឺដោយសមាជិក គជប សវនាការសង្ខេបនេះ គឺជាសវនាការធ្វើឡើងដើម្បីដោះស្រាយចំពោះតែវិវាទអង្គច្បាប់ប៉ុណ្ណោះ មានន័យថា គជប ដោះស្រាយបណ្តឹងដោយផ្អែកលើមូលដ្ឋាននៃបញ្ញត្តិដែលមានចែងក្នុងច្បាប់បោះឆ្នោត (ច្បាប់បោះឆ្នោតទាំងពីរ និងច្បាប់ស្តីពីការរៀបចំប្រព្រឹត្តទៅនៃ គជប) ប៉ុណ្ណោះ។ ផ្អែកតាមបញ្ញតិដែលមានចែងក្នុងបទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត ប្រការ៥.១៥ គឺ គ.ជ.ប មានជម្រើសក្នុងការអនុវត្តប្រភេទនៃនីតិវិធីនៃការជំនុំជម្រះ។ ប្រភេទនៃនីតិវិធីជំនុំជម្រះ រួមមានសវនាការសង្ខេប សវនាការតទល់ និងសវនាការសួរដេញដោល។

តាមការណ៍សង្កេត ក្នុងរយៈពេលបីថ្ងៃ នៃសវនាការសាធារណៈនេះ គ.ជ.ប បានបើកចំហរអោយសាធារណៈជន អ្នកសារព័ត៌មាន គណបក្សនយោបាយក្នុងការតាមដាន ស្តាប់នូវការប្រព្រឹត្តទៅនៃអង្គសវនាការលើបណ្តឹង ប៉ុន្តែ គ.ជ.ប មិនបានបើកចំហ អោយមានការសាកសួរសំណួរផុសផុលពីអ្នកចូលរួម ឬអ្នកសារព័ត៌មានអំពីរឿងផ្សេងៗក្នុងដំណើរការដោះស្រាយនោះឡើយ ហើយនីតិវិធីនៃការសួរដេញដោលក៏មិនបានអនុវត្តផងដែរ។ បញ្ហាដែលសំខាន់បំផុតគឺដំណើរការដោះស្រាយបណ្តឹង អត្តវត្តមានចុងចម្លើយ (ជនដែលត្រូវគេចោទប្រកាន់) ក្នុងការសួរដេញដោលគ្នាក្នុងសវនការ។ អ្នកកាសែត ត្រូវបានអនុញ្ញាតអោយចូលស្តាប់ និងតាមដាន ប៉ុន្តែមិនត្រូវបានអនុញ្ញាតិអោយថតរូប និងអាត់សំឡេង ឬវីដេអូរអ្វីទាំងអស់ក្នុងពេលកំពុងសវនាការ។ ក្នុងរយៈពេលបីថ្ងៃនៃដំណើរការនីតិវិធី សវនាការសាធារណៈនេះ គ.ជ.ប ចេញលិខិតអញ្ជើញទៅគូភាគីនៃបណ្តឹងស្របទៅតាមបទបញ្ជា និងនីតិវិធីនៃការដោះស្រាយបណ្តឹង។ ប៉ុន្តែការសង្កេតឃើញថា ស្ទើរគ្រប់បណ្តឹង ឬសំណុំរឿង គឺមិនមានវត្តរបស់ចុងចម្លើយដើម្បីឆ្លើយបំភ្លឺតបទៅនឹងការចោទប្រកាន់របស់ដើមបណ្តឹង។ គួរកត់សំគាល់ថា ក្នុងរយៈពេល១ថ្ងៃដំបូង គ.ជ.ប ហាក់មានការបើកទូលាយខ្លះដើម្បីគោរពទៅតាមនីតិវិធីនៃសវនាការ ប៉ុន្តែដោយសារការសួរសំណួរ ការជជែកវែកញែកមួយចំនួនពាក់ព័ន្ធនឹងបញ្ហារសើប ជ្រៅពេក វាបានចំណាយពេលវេលាច្រើន និងផុសផុលខ្លាំង ទើប គ.ជ.ប សម្រេចប្តូរនីតិវិធីសវនាការរបស់ខ្លួន។ គិតត្រឹមថ្ងៃទី១៨ មករា ឆ្នាំ២០១៧ គ.ជ.ប ទទួលបានបណ្តឹងសរុបចំនួន ១៤៧បណ្តឹង ទាំងបណ្តឹងតវ៉ា និងបណ្តឹងជំទាស់ ក្នុងនោះដោះស្រាយបានចំនួន ៣៩បណ្តឹង ជាទូទៅបណ្តឹងតវ៉ាត្រូវបានដោះស្រាយ។ សម្រាប់បណ្តឹងដែលសេសសល់គឺជា

បណ្ដឹងជំទាស់ដែលត្រូវបានដោះស្រាយតាមរយៈសវនាការជាសាធារណៈក្នុងរយៈពេលបីថ្ងៃ ហើយការជំនុំជម្រះត្រូវបានបិទបញ្ចប់ដល់យប់ជ្រៅ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចប្ដូរនីតិវិធីដោះស្រាយបណ្ដឹងពីសវនាការជាសាធារណៈទៅជាសវនាការសង្ខេបចាប់ពីថ្ងៃទី១៩មករា ឆ្នាំ២០១៧។ ការផ្លាស់ប្ដូរនេះ គ.ជ.ប បានលើកហេតុផលថា ខ្លួនបានពិនិត្យទៅលើប្រភេទនៃពាក្យបណ្ដឹង ប្រសិនបណ្ដឹងនោះទាក់ទងនឹងច្បាប់ដែលមានចែងស្រាប់ គ.ជ.ប នឹងដោះស្រាយតាមរយៈសវនាការសង្ខេប។ ប៉ុន្តែប្រសិនបើបណ្ដឹងនោះទាក់ទងអង្គហេតុដែលត្រូវការព័ត៌មានបន្ថែមនឹងដោះស្រាយតាមរយៈសវនាការសាធារណៈ។ ក្រោយពីថ្ងៃទី១៩ រហូតដល់ថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ២០១៧ គ.ជ.ប បានប្រើនីតិវិធីដោះស្រាយបណ្ដឹង ជាប្រភេទសវនាការសាធារណៈ ដោយលើកហេតុផលថា ការប្ដូរនីតិវិធីនៃការដោះស្រាយនេះដើម្បីចំណេញពេលវេលា និងពន្លឿនការដោះស្រាយ ខណៈបណ្ដឹងមានច្រើន។ តាមការសង្កេត ការដោះស្រាយបណ្ដឹងតាមរយៈសវនការសង្ខេបនេះ គឺមិនបានអនុញ្ញាតិអោយសាធារណៈជន អ្នកសង្កេតការណ៍សង្គមស៊ីវិល គណក្សបក្ស និងសូម្បីតែដើមបណ្ដឹង និងចុងចម្លើយ បានចូលក្នុងសវនការឡើយ ក្រៅតែពីមន្ត្រីដោះស្រាយបណ្ដឹង មន្ត្រីជំនាញរបស់ខ្លួន និងសមាជិក គ.ជ.ប ដែលទទួលបន្ទុកដោះស្រាយបណ្ដឹងទាំងនោះ។ គ្មានករណី ឬបណ្ដឹងជំទាស់ណាមួយត្រូវបានស៊ើបអង្កេតដោយ គ.ជ.ប ឡើយក្នុងរយៈពេលដែលខ្លួនបានដោះស្រាយបណ្ដឹងនៅក្នុងអាណត្តិរបស់ខ្លួន។ ផ្អែកតាមបទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត បន្ទាប់ពីថ្ងៃទទួលពាក្យបណ្ដឹង គ.ជ.ប មានរយៈពេល០៥ថ្ងៃ ដើម្បីដោះស្រាយបណ្ដឹងនោះ។ ថ្លែងទៅកាន់អ្នកចូលរួមសន្និសីទការសែតនៅថ្ងៃទី១៩ លោក មាន សាទិ បានបញ្ជាក់ថា៖ « *ដោយសារបណ្ដឹងដែលបានដោះស្រាយកន្លងមកទាំងបីថ្ងៃជារឿងដោះស្រាយបណ្ដឹងអង្គច្បាប់ ដូច្នេះហើយ គ.ជ.ប រៀបចំប្ដូរយន្តការដោះស្រាយវិញព្រោះថា រយៈពេលខ្លី បណ្ដឹងមានច្រើន អ៊ីចឹងបណ្ដឹងតទៅទៀតដែលពាក់ព័ន្ធតែអង្គច្បាប់យើងដោះស្រាយសង្ខេប បើបណ្ដឹងទាក់ទងអង្គច្បាប់ និងអង្គហេតុផងយើងនឹងធ្វើឡើងវិញតាមសវនាកាជាសាធារណៈ*»។

សរុបរយៈពេលនៃការដោះស្រាយបណ្ដឹងតវ៉ា និងបណ្ដឹងជំទាស់ គ.ជ.ប បានប្រើរយៈពេលបីថ្ងៃលើនីតិវិធីជំនុំជម្រះសវនាការសាធារណៈ (ថ្ងៃទី១៦ ដល់ ១៨ ខែមករា ឆ្នាំ២០១៧ និងចំនួន០៦ថ្ងៃ លើនីតិវិធីជំនុំជម្រះសវនាការសង្ខេបថ្ងៃទី១៩ ដល់ទី២៤ ខែមករា ឆ្នាំ២០១៧) លើបណ្ដឹងសរុប ១៧៣បណ្ដឹង ដែលទាក់ទងនឹងអ្នកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតដំបូងសរុបចំនួន ២៤៧៩នាក់។ បណ្ដឹងទាំងនេះត្រូវបានប្ដឹងដោយដើមបណ្ដឹង (បណ្ដឹងតវ៉ា និងបណ្ដឹងជំទាស់) ជំទាស់នឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃក្រុមប្រឹក្សាឃុំ សង្កាត់ (ហៅកាត់ថា កបឃ.ស)។ ក្នុងចំណោមបណ្ដឹងទាំង១៧៣ មាន១៦៥បណ្ដឹង គឺជាបណ្ដឹងជំទាស់ ដែលប្ដឹងដោយសកម្មជនរបស់គណបក្សសង្គ្រោះជាតិសុំលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីឈ្មោះបោះឆ្នោតដំបូងសរុប ២៤៤១នាក់ និងមាន០៧បណ្ដឹង ជាបណ្ដឹងតវ៉ា ប្ដឹងសុំរក្សាទុកឈ្មោះ ៣៨នាក់ និង០១បណ្ដឹងទៀតជាបណ្ដឹងសុំអោយផ្ដន្ទាទោសតាមទោសបញ្ញត្តិដែលមានចែងក្នុងច្បាប់បោះឆ្នោត។ គ.ជ.ប បានដោះស្រាយរួចរាល់ចំនួន ១៧២បណ្ដឹង និងនៅសល់ ០១បណ្ដឹង ជាបណ្ដឹងពាក់ព័ន្ធនឹងការស្នើសុំអោយផ្ដន្ទាទោស។ ការដោះស្រាយបណ្ដឹងជំទាស់ទាំង ១៦៥បណ្ដឹង ដែលស្នើសុំអោយលុបឈ្មោះអ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតដំបូង គឺត្រូវបានដោះស្រាយដោយ គ.ជ.ប និងបានសម្រេចរក្សាទុកឈ្មោះជនដែលត្រូវបានចោទប្រកាន់ក្នុងបណ្ដឹងទាំង ១៦៥នោះដដែល មានន័យថា គ.ជ.ប មិនបានលុបឈ្មោះជនណាម្នាក់ពីបញ្ជឈ្មោះតបតាមបណ្ដឹងស្នើសុំឡើយ។ ហេតុផលសំខាន់មួយដែល គ.ជ.ប បានលើកឡើងក្នុងសេចក្ដីសម្រេច

របស់ខ្លួន គឺដើមបណ្តឹងនៃបណ្តឹងជំទាស់ទាំង១៦៥ គ្មានមូលដ្ឋានភស្តុតាងគតិយុត្តដោយសារថា ជនដែលត្រូវបានចោទប្រកាន់ថាជាជនបរទេស (ជនជាតិវៀតណាម) ទាំងនោះ គឺសុទ្ធតែបានប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដើម្បីចុះឈ្មោះបោះឆ្នោតទាំងអស់។ គ.ជ.ប បានអះអាងថា ខ្លួនបានប្រើប្រាស់អំណាច និងអនុវត្តតួនាទី និងភារកិច្ច សមត្ថកិច្ច ត្រឹមតែច្បាប់បោះឆ្នោត និងច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ គ.ជ.ប ចែងប៉ុណ្ណោះ មិនមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតស៊ីជម្រៅទៅលើភាពស្របច្បាប់ ឬមិនស្របច្បាប់នៃការកាន់កាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ នៃជនដែលត្រូវបានគេប្តឹងចោទប្រកាន់ទាំងនោះឡើយ និងជាការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ។ ទោះជាយ៉ាងណា គ.ជ.ប បានដាក់លិខិតទៅកាន់ក្រសួងមហាផ្ទៃ និងភ្ជាប់ដោយបញ្ជីឈ្មោះចុងចម្លើយ (ចុងចោទ) ដើម្បីស្នើសុំក្រសួងមហាផ្ទៃជួយបញ្ជាក់ និងពិនិត្យបន្ថែមអំពីភាពស្របច្បាប់នៃការកាន់កាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ពួកគេ។ ជាការឆ្លើយតប ក្រសួងមហាផ្ទៃបានអះអាងថា (រកលិខិតឆ្លើយតាមរបស់ក្រសួងមហាផ្ទៃមិនឃើញ កំពុងស្វែងរក)។

## ក.៩.២. ការដោះស្រាយបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ (ក.ប.ធ)

យោងតាមបទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ អ្នកប្តឹង ឬតំណាងដែលមិនសុខចិត្តនឹងសេក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលទម្រង់សេចក្តីសម្រេចរបស់ គ.ជ.ប (ទ.១២០៣)។ តាមន័យ ដើមបណ្តឹង គឺគណបក្សសង្គ្រោះជាតិ បានដាក់ពាក្យបណ្តឹងជាបន្តបន្ទាប់ទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ ជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ដែលមិនលុបឈ្មោះជនដែលត្រូវបានប្តឹង និងចោទប្រកាន់ថាកាន់កាប់អត្តសញ្ញាណប័ណ្ណ មិនប្រក្រតី។ យោងតាមបទបញ្ជា និងនីតិវិធីនេះ ក្រុមប្រឹក្សាធមម្មនុញ្ញ បន្ទាប់ពីទទួលពាក្យបណ្តឹងពីអ្នកប្តឹង ខ្លួនមានរយៈពេល១០ថ្ងៃ ក្នុងការដោះស្រាយពាក្យបណ្តឹងនោះ។

ក.ប.ធ បានចាប់ផ្តើមទទួលពាក្យបណ្តឹងចាប់ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ និងបានចាប់ផ្តើមដោះស្រាយបណ្តឹងទាំងនោះចាប់ពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧។ យោងតាមការសម្រេចលើសំណុំរឿង ដែល ក.ប.ធ បានចុះផ្សាយលើគេហទំព័ររបស់ខ្លួន សំណុំរឿងពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹងបោះឆ្នោតដែលចុះលេខដោយ ក.ប.ធ មាន២៤សំណុំរឿង។ ក្នុងរយៈពេល ០៣ថ្ងៃដំបូង (ថ្ងៃទី៣០, ៣១ ខែមករា និងថ្ងៃទី០១ ខែកុម្ភៈឆ្នាំ២០១៧ ក.ប.ធ បានបើកសវនការជំនុំជម្រះជាសាធារណៈដោយបើកអោយមានការចូលរួមពីមហាជន។ អ្នកចូលរួមស្តាប់ ៥០នាក់ ដើមណ្តឹង និងចុងចម្លើយ (គ.ជ.ប) ដោយធ្វើការដោះស្រាយបានចំនួន ១១បណ្តឹងទាក់ទងនឹងការសម្រេចរបស់ គ.ជ.ប ដែលបានធ្វើឡើងជា សាធារណៈក្នុងចន្លោះថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ លើការទាមទារអោយមានការលុបឈ្មោះអ្នកមានឈ្មោះក្នុងបញ្ជីចំនួន ៥៦៨នាក់។ លទ្ធផលនៃការដោះស្រាយបណ្តឹងក្រុមប្រឹក្សាជំនុំជម្រះរបស់ ក.ប.ធ បានយល់ឃើញថា ក្រុមប្រឹក្សាបានសម្រេចដោយមានមូលដ្ឋានគតិយុត្តិត្រឹមត្រូវ រីឯដើមបណ្តឹងដែលតំណាងដោយលោក ផេង ហេង លោក កាក់ កុម្ភារ និងលោកស្រី ម៉េង សុភារី ជាមេធាវី ពុំមានឯកសារ ឬភស្តុតាងជាលាយលក្ខណ៍អក្សរដែលអាចអោយក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចរបស់ គ.ជ.ប បានឡើយ។ ការសម្រេចលើបណ្តឹងទាំង ១១នេះ ក.ប.ធ ក៏បានបញ្ជារឱ្យមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានរបស់ខ្លួន ចុះស៊ើបអង្កេត។ ក.ប.ធ អះអាងថា ពលរដ្ឋដែលត្រូវបានភ្ជាក់ងារគណបក្សសង្គ្រោះជាតិ ប្តឹងសុទ្ធតែបានបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតគ្រប់គ្រាន់តាមច្បាប់ បទបញ្ជា និងនីតិវិធីចុះឈ្មោះបោះឆ្នោត។

ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ ក.ប.ធ បានផ្លាស់ប្តូរនីតិវិធីនៃសវនការសាធារណៈមកជាសវនការអសាធារណៈ កិច្ចប្រជុំពេញអង្គ ដែលកិច្ចប្រជុំពេញអង្គសម្រេចលើបណ្តឹងនេះ គឺមិនមានភាគីដើមចោទ និងតំណាង គ.ជ.ប ចូលរួមឡើយ។ កិច្ចប្រជុំពេញអង្គនេះ គឺប្រជុំសម្រេចលើបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ចំនួន

១០៨សំណុំរឿង។ បណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទាំង១០៨នេះមាន ១០៤សំណុំរឿង ជាបណ្តឹងសុំលុបឈ្មោះមនុស្សចំនួន ១៣៧៦នាក់ និង ០៤សំណុំរឿងផ្សេងទៀត ជាបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ពាក់ព័ន្ធនឹងការសុំរក្សាឈ្មោះមនុស្សចំនួន ៣៤នាក់ ដែលត្រូវបាន គ.ជ.ប សម្រេចដាក់ក្នុងបញ្ជីលុប ក្នុងបញ្ជីឈ្មោះបោះឆ្នោតបឋម។ ជាលទ្ធផល ក.ប.ធ បានសម្រេចលើ ១០៥សំណុំរឿង ទុកជាបានការពេញទាំងមូល ហើយតម្កល់សេចក្តីសម្រេចរបស់ គ.ជ.ប លើ ០៣សំណុំរឿងទៀត ទុកជាបានការ ប៉ុន្តែបានលុបឈ្មោះចំនួន ០៣នាក់ ក្នុងចំណោមឈ្មោះសរុប ១៤១០នាក់ ដែលមានក្នុងបណ្តឹង ព្រោះឈ្មោះទាំង ០៣នាក់នោះពុំមានក្នុងបញ្ជីបោះឆ្នោតដំបូង។ ក្រៅពីនេះ ក.ប.ធ ក្រុមប្រឹក្សាជំនុំជម្រះក៏បានច្រានចោលបណ្តឹងជំទាស់នឹងសម្រេចរបស់ គ.ជ.ប លើ០៨ សំណុំរឿងផ្សេងទៀត ដោយហេតុថា បណ្តឹងទាំងនោះ ខុសនឹងទម្រង់ច្បាប់។

ក្នុងការដោះស្រាយនឹងបណ្តឹងសុំអោយមានការលុបឈ្មោះទាំងអស់ គ.ជ.ប បានបញ្ជាក់មូលហេតុថា ខ្លួនគ្មានសមត្ថកិច្ចក្នុងការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ទេ។ លោក អ៊ុត ឈន អ្នកនាំពាក្យក្រុមប្រឹក្សាធម្មនុញ្ញ *«យើងនិយាយពីរឿងច្បាប់ ដំណាក់កាលនេះជាដំណាក់កាលអី។ ជាដំណាក់កាល ពិនិត្យបញ្ជីសេចក្តីសម្រេចរបស់ គ.ជ.ប ឈ្មោះ ក្រោយគេប្រកាសផ្សាយ។ ចឹងក្នុងការពិនិត្យបញ្ជីឈ្មោះ តាមច្បាប់កាលណាគេចុះផ្អែកតាមមាត្រា ៤៦ អ្នកនោះឯងមានអត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់អត្តសញ្ញាណ។ ចឹងក្រុមប្រឹក្សាធម្មនុញ្ញ មានភារកិច្ចផែកលើច្បាប់ហ្នឹង។ បើយើងផែកឃើញថា រាល់ការសម្រេចរបស់ គ.ជ.ប គឺសុទ្ធតែផ្អែកតាមច្បាប់ហ្នឹង មានឯកសារបញ្ជាក់អត្តសញ្ញាណជាតិខ្មែរ កាលហ្នឹងគេមានមូលដ្ឋានហ្នឹង យើងទទួលរបស់គេហើយ»*។

អ្នកស្រី ម៉េង សុភារី ប្រធាននាយកដ្ឋានកិច្ចការបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ បង្ហាញអារម្មណ៍នៃការសោកស្តាយចំពោះការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលផ្អែកទៅលើអង្គច្បាប់ ឬឯកសារបញ្ជាក់សញ្ជាតិតែមួយមុខនោះ។ អ្នកស្រីថា ក្រុមប្រឹក្សាធម្មនុញ្ញ និងស្ថាប័នពាក់ព័ន្ធ គប្បីធ្វើការស៊ើបអង្កេតលើបញ្ហាទាំងនេះឲ្យបានស៊ីជម្រៅជាងនេះ។ លោកស្រីបញ្ជាក់ថា *«ការប្តឹងនេះ គឺយើងយោងទៅលើលក្ខខណ្ឌសញ្ជាតិ។ ដើម្បីអាចមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានលុះត្រាតែមានសញ្ជាតិខ្មែរ ចឹងផ្អែកលើមាត្រានេះ ភ្នាក់ងារគណបក្សសង្គ្រោះជាតិ បានប្តឹងសុំឲ្យយកមាត្រាហ្នឹងមកធ្វើការពិចារណា។ ប៉ុន្តែត្រូវបានស្ថាប័នដោះស្រាយវិវាទទាក់ទងនឹងការចុះឈ្មោះបោះឆ្នោតគ្រប់ជាន់ថ្នាក់ច្រានចោលទាំងអស់»*។

ជាសរុប ក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលបើសវនការដោះស្រាយ ទាំងសាធារណៈ និងអសាធារណៈ(សង្ខេប) លើបណ្តឹងជំទាស់នឹងការសម្រេចរបស់ គ.ជ.ប អំពីការបដិសេធលុបឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតដែលប្តឹងដោយមន្ត្រីគណបក្សសង្គ្រោះជាតិ ក្រុមប្រឹក្សានៃ ក.ប.ធ បានតម្កល់សេចក្តីសម្រេចលើសំណុំរឿងជំទាស់នឹងសម្រេចរបស់ គ.ជ.ប ចាត់ទុកជាបានការហើយសេចក្តីសម្រេចនេះជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

## ខ. ការឃ្លាំមើលលើបទបញ្ជា និងនីតិវិធីក្នុងដំណើរការចុះឈ្មោះបោះឆ្នោត

ក្នុងការសង្កេតដំណើរការចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែល សហការជាមួយសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) មានដូចជា អង្គការ និកហ្វិក អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) បានបញ្ជូនរបាយការណ៍ដែលរកឃើញករណីភាពមិនប្រក្រតី សរុបចំនួន ១៥៥៤០ករណី ពីអ្នកសង្កេតការណ៍ សរុបចំនួន ៥៤៦នាក់ ត្រូវនឹង ៥៤៦ឃុំសង្កាត់ (លទ្ធផលដែលទទួលបានមិនតំណាង ឬជាសំណាកនោះទេ វាគ្រាន់តែជាករណីដែលរកឃើញក្នុងទីតាំង

កំណត់)ក្នុងនោះអ្នកសង្កេតការណ៍ដែលធ្វើការរយៈពេល ១២ថ្ងៃ មានចំនួន ២៤២នាក់ និងអ្នកសង្កេតការណ៍ធ្វើការរយៈពេល៣ថ្ងៃ មានចំនួន ៣០៤នាក់។




## កំណត់សំគាល់

| កូដ | ប្រភេទករណី | ករណី | % |
|---|---|---|---|
| ក.១ | ការិយាល័យ**មិនមានសណ្តាប់ធ្នាប់ដោយមិនបានតម្រង់ជួរ និងរញ៉េរញ៉ៃចូលការិយាល័យ** | 4306 | 27.7% |
| ក.២ | មន្ត្រី ក.ច.ប មិនបានអនុវត្តតាមនីតិវិធីត្រឹមត្រូវ ដូចជាប្រធានមិនសំភាសន៍ អនុប្រធានបំពេញទម្រង់បង្កាន់ដៃខុស និងសរសេរខុសច្រើន ការីកុំព្យូទ័របញ្ចូលខុសទិន្នន័យ | 3194 | 20.6% |
| ក.៣ | អ្នកសុំចុះឈ្មោះ**មិនពិនិត្យ និងផ្ទៀងផ្ទាត់ឈ្មោះ**របស់គាត់ជាមួយអេក្រង់កុំព្យូទ័រ | 3739 | 24.1% |
| ក.៤ | មាន **ប៉ូលិស ទាហាន ឬអ្នកពាក់អាវមានសញ្ញាគណបក្សនយោបាយ** ដែលបានបង្ហាញដល់ការគាំទ្រចូលក្នុងការិយាល័យចុះឈ្មោះ និងនៅបរិវេណខាងក្រៅការិយាល័យ | 199 | 1.28% |
| ក.៥ | អ្នកគ្មានតួនាទីចូលក្នុងការិយាល័យបោះឆ្នោតនិងអ្នកខ្លះចូលទាក់ទងស្មៀនធ្វើកិច្ចការរដ្ឋបាល ការចូលសុំព័ត៌មាន នគរបាលខ្លះចូលរៀបចំសណ្តាប់ធ្នាប់ ជាដើម | 232 | 1.49% |

| | | | |
|---|---|---|---|
| ក.៦ | មានការរាំងស្ទះដល់ដំណើរការចុះឈ្មោះបោះឆ្នោត ដោយសារតែភាពរអាក់រអួលនៃសម្ភារៈ និងមន្ត្រីមានការធ្វេសប្រហែសក្នុងការបញ្ចូល | 83 | 0.53% |
| ក.៧ | ករណីដែលរកឃើញពីការរារាំងអ្នកសង្កេតការណ៍ មិនឲ្យចូលរួមសង្កេត | 3 | 0.02% |
| ក.៨ | កន្លែងដែលសង្កេតឃើញមន្ត្រីចុះឈ្មោះខ្លះធ្វើការមិនគ្រប់ចំនួន(តែមួយរយៈខ្លី) | 177 | 1.14% |
| ក.៩ | អនុប្រធានបានសរសេរខុសទិន្នន័យក្នុងបង្កាន់ដៃអ្នកចុះឈ្មោះបោះឆ្នោត | 499 | 3.21% |
| ក.១០ | ប្រធាន ក.ច.ប បដិសេធការសុំចុះឈ្មោះ ដោយមិនឲ្យ«ទម្រង់បដិសេធ» ឬមិនបញ្ជាក់ពីមូលហេតុទៅអ្នកសុំចុះឈ្មោះ | 310 | 1.99% |
| ក.១១ | អនុប្រធាន ក.ច.ប មិនបានណែនាំអ្នកសុំចុះឈ្មោះបោះឆ្នោត ទៅជួបការីកុំព្យូទ័រ | 1313 | 8.45% |
| ក.១២ | មន្ត្រីការីកុំព្យូទ័រ មិនផ្តិតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដោយត្រឹមត្រូវ | 162 | 1.04% |
| ក.១៣ | អ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានទទួលបង្កាន់បញ្ជាក់ការចុះឈ្មោះបោះឆ្នោត | 23 | 0.15% |
| ក.១៤ | ករណីដែលអ្នកបានចុះឈ្មោះម្តងហើយបានមកចុះឈ្មោះម្តងទៀត | 33 | 0.21% |
| ក.១៥ | ដែលមានបញ្ហារអាក់រអួល រហូតដល់បញ្ឈប់ដំណើរការចុះឈ្មោះ ចាប់ពី៣០ នាទីឡើងទៅ | 105 | 0.68% |
| ក.១៦ | មានប្រជាពលរដ្ឋជាច្រើននាក់ដែលរស់នៅក្នុងសហគមន៍ ឬក្នុងភូមិណាមួយ ដែលមិនបានចុះឈ្មោះបោះឆ្នោត ក្រោយរយៈពេលបញ្ចប់នៃការចុះឈ្មោះ បញ្ហាបណ្តាលពីពេលវេលា និងព័ត៌មានមិនគ្រប់គ្រាន់ | 104 | 0.67% |
| ក.១៧ | ករណីបដិសេធចំពោះអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតស្របច្បាប់ មិនឲ្យចុះឈ្មោះ ដោយសារខ្វះលក្ខខណ្ឌឯកសារ | 449 | 2.89% |
| ក.១៨ | ចុះឈ្មោះដល់អ្នកពុំមានសិទ្ធិចុះឈ្មោះបោះឆ្នោត គាត់មិនពិនិត្យអាយុ ជនជាតិវៀតណាមកាន់អត្តសញ្ញាណបណ្ណ | 23 | 0.15% |
| ក.១៩ | ការបំភិតបំភ័យ និងគំរាមកំហែងប្រជាពលរដ្ឋមិនឲ្យមកចុះឈ្មោះ | 0 | 0.00% |
| ក.២០ | មានការរារាំង/ទប់ស្កាត់/អុកឡុករំខាន មិនឲ្យមកចុះឈ្មោះបោះឆ្នោត | 4 | 0.03% |
| ក.២១ | មន្ត្រីការីកុំព្យូទ័របញ្ចូលទិន្នន័យខុស | 194 | 1.25% |
| ក.២២ | បញ្ហាបញ្ជូនទិន្នន័យពីការិយាល័យមកមជ្ឈមណ្ឌលកុំព្យូទ័រ | 388 | 2.50% |
| **សរុប** | | **15540** | **100.0%** |

## ខ.១ បរិយាកាសនៃដំណើរការចុះឈ្មោះបោះឆ្នោត

### ខ.១.១ បញ្ហាសន្តិសុខ

ក្នុងការិយាល័យដែលបានសង្កេត អ្នកសង្កេតការណ៍ សង្កេតឃើញអ្នកមកសុំចុះឈ្មោះបោះឆ្នោត ១៩៩ (១.២៨%)ករណី មានស្លៀកពាក់ឯកសណ្ឋាន ដូចជា ប៉ូលីស យោធា ឬពាក់អាវមានសញ្ញាគណបក្សនយោបាយ ដែលបានបង្ហាញដល់ការគាំទ្រចូលក្នុងការិយាល័យចុះឈ្មោះ និងក្បែរនោះផងដែរ ដែលរំលោភបទបញ្ញា និងនីតិវិធីចុះឈ្មោះបោះឆ្នោតប្រការ៣.៤ ចំណុច៣.៥.៤ ចំណុច៣.៥.៦ និងមាត្រា៥២ នៃ ច.ប.ត.រ។

**១៩៩** (១.២៨%) **ករណី** មានស្លៀកពាក់អាវ ប៉ូលីស យោធា និងមានផ្លាកសញ្ញាគណបក្ស



តែទោះបីយ៉ាងណាការសង្កេតមិនបានរកឃើញករណីបំភិតបំភ័យ និងការគំរាមកំហែង ឬករណីបង្កឲ្យមានរបួតដល់ការរារាំង/អុកឡុករំខានដល់ប្រជាពលរដ្ឋមិនឲ្យទៅចុះឈ្មោះនោះទេ។

### ខ.១.២ សណ្តាប់ធ្នាប់

**អ្នកចុះឈ្មោះបោះឆ្នោតមិនបានតម្រង់ជួរ**




ទាក់ទងសណ្តាប់ធ្នាប់នេះផងដែរ អ្នកសង្កេតការណ៍បានសង្កេតឃើញថា ការិយាល័យ

មួយចំនួន មិនបានរៀបចំប្រជាពលរដ្ឋឈរតម្រង់ជួរឲ្យបានត្រឹមត្រូវនោះទេ ក្នុងរយៈពេល និងទីកន្លែងដែលបានសង្កេត ករណីនេះអ្នកសង្កេតការណ៍សង្កេតឃើញមានចំនួន ៤៣០៦ករណី ដែលមិនគោរពតាមបទបញ្ញា និងនីតិវិធីចុះឈ្មោះបោះឆ្នោតប្រការ៤.៤ នៃចំណុច ៤.៤.៨ របស់ ប.ន.ប.ថ។

ទាក់ទងសណ្ដាប់ធ្នាប់ អ្នកសង្កេតការណ៍បានសង្កេតឃើញថា មានអ្នកដែលគ្មានតួនាទី ចូលក្នុង ឬក្រៅការិយាល័យចុះឈ្មោះបោះឆ្នោតយ៉ាងហោចណាស់មាន ចំនួន ២៣២ ករណី ដែលគេស្គាល់គាត់ថាជាតំណាងរបស់គណបក្សនយោបាយ និងបានដើររញ៉េរញ៉ៃទៅពិនិត្យឈ្មោះដោយរំខានការចុះឈ្មោះរបស់ប្រជាពលរដ្ឋក្នុងអំឡុងពេល និងទីតាំងសង្កេតដែលមាននៅក្នុងប្រការ៣.៤ និងចំណុច ៣.៥.៥ នៃ ប.ន.ប.ថ។



រូបភាពពី ហ្វេសប៊ុក

## ខ.២ ដំណើរការចុះឈ្មោះបោះឆ្នោត

### ខ.២.១. ពេលវេលានៃការចុះឈ្មោះបោះឆ្នោត

ការចុះឈ្មោះបោះឆ្នោត ត្រូវបានកំណត់នៅក្នុងបទបញ្ញា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ ២០១៦ (ប.ន.ប.ថ) ដែលបានបង្ហាញពីពេលវេលាធ្វើការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ ដូចបានកំណត់ក្នុងប្រការ ៤.២។

ទាក់ទងបញ្ហាពេលវេលាសម្រាប់ការចុះឈ្មោះបោះឆ្នោតនេះ អ្នកសង្កេតការណ៍សង្កេតបានឃើញថា មានការិយាល័យខ្លះបើកដំណើរការយឺតយ៉ាវ(នៅម៉ោងជិត៨)។ រីឯពេលល្ងាចក៏មានមានការិយាល័យខ្លះបិទមុនម៉ោងកំណត់ផងដែរ។ ជាក់ស្ដែងដូចជានៅដូចជានៅក្នុងឃុំព្រះពន្លាស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឃុំតាគោក ស្រុកសំឡូត ខេត្តបាត់ដំបង ឃុំទួលគគីរ ខេត្តកោះកុង ឃុំស្វាយរមៀត ស្រុខខ្សាច់កណ្ដាល ខេត្តកណ្ដាល និងនៅខេត្តរតនគិរី។



រូបភាពលេខាខេត្តកោះកុង

បន្ថែមលើករណីនេះ សម្រាប់នៅក្នុងខេត្តរតនគិរី អ្នកសង្កេតការណ៍សង្កេតឃើញមានភាពមិនប្រក្រតីក្នុងយុទ្ធនាការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតមួយចំនួន គ្រាដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) តម្រូវឲ្យក្រុមការងារចុះឈ្មោះបោះឆ្នោតគ្រប់ខេត្ត-រាជធានី ឈប់សម្រាកពីរថ្ងៃនៃពិធីបុណ្យភ្ជុំបិណ្ឌ។ គ.

គ.ជ.ប បានសម្រេចឲ្យក្រុមការងារចុះឈ្មោះបោះឆ្នោតនៅគ្រប់ការិយាល័យតាមបណ្តាខេត្ត-រាជធានីឈប់សម្រាកពីរថ្ងៃ គឺចាប់ពីថ្ងៃទី៣០ កញ្ញា ដល់ថ្ងៃទី១ តុលា ដែលជាថ្ងៃបុណ្យភ្ជុំ ហើយធ្វើការមួយថ្ងៃចុងក្រោយនៃថ្ងៃឈប់សម្រាក គឺចាប់ពីថ្ងៃទី២ តុលា។

តែការិយាល័យចុះឈ្មោះបោះឆ្នោតចំនួនបីនៅក្រុងបានលុង និងមួយការិយាល័យនៅឃុំសេដា ស្រុកលំផាត់ មិនបានធ្វើតាមការណែនាំនេះទេ ក្នុងនោះការិយាល័យចំនួនពីរ គឺការិយាល័យសង្កាត់ឡាបានសៀក និងការិយាល័យឃុំសេដា ស្រុកលំផាត់ បិទការិយាល័យក្នុងថ្ងៃចុះឈ្មោះ និងការិយាល័យសង្កាត់កាចាញ និងសង្កាត់យក្សឡោម មន្ត្រីការិយាល័យចុះឈ្មោះបោះឆ្នោតខ្លះអវត្តមាន ហើយគ្មានអ្នកជំនួស។

### ខ.២.២. សមាសភាពអ្នកសង្កេតការណ៍នៃកន្លែងចុះឈ្មោះបោះឆ្នោត

ការសង្កេតការណ៍រកឃើញថា ភ្នាក់ងារគណបក្សនយោបាយបានចូលរួមគ្រប់គ្រប់ការិយាល័យចុះឈ្មោះបោះឆ្នោត ក្នុងការិយាល័យដែលខុមហ្វ្រែលបានសង្កេត។ ក្នុងនោះ ខុមហ្វ្រែលសង្កេតឃើញមានភ្នាក់ងារគណបក្សប្រជាជន ភ្នាក់ងារគណបក្សសង្គ្រោះជាតិ។ រីឯអ្នកសង្កេតការណ៍មកពីអង្គការ និងសមាគម មិនមែនរដ្ឋាភិបាល សង្កេតឃើញថាមានការចូលរួមតិចតួច។

សម្រាប់ករណីទាក់ទងការរារាំងអ្នកសង្កេតការណ៍ ខុមហ្វ្រែលសង្កេតឃើញមាន ៣ករណី ដែលហាមមិនឲ្យអ្នកសង្កេតការណ៍ឈរពីខាងក្រោយការីកុំព្យូទ័រ ដោយសារតែកុំព្យូទ័រមានបញ្ហា ធ្វើឲ្យគាត់ខឹង និងសុំឲ្យអ្នកសង្កេតការណ៍អង្គុយឲ្យស្ងៀម និង២ករណីហាមភ្នាក់ងារគណបក្សនយោបាយមិនឲ្យពិនិត្យលិខិតបញ្ជាក់ទីលំនៅ និងករណីចុងក្រោយ គឺហាមឃាត់មិនឲ្យអ្នកសង្កេតការណ៍ខុមហ្វ្រែលមិនឲ្យសង្កេតនៅក្នុងឃុំជំនាប់ ស្រុកថ្មបាំង ដោយប្រាប់ឲ្យទៅស្នើសុំលិខិតបញ្ជាក់ ទោះបីអ្នកសង្កេតការណ៍មានកាតបញ្ជាក់ពី គ.ជ.ប មកបង្ហាញដល់ពួកគាត់យ៉ាងណាក៏ដោយ តែទោះបីយ៉ាងណាមន្ត្រីលេខាធិការដ្ឋានខេត្តកោះកុងបានជួយអន្តរាគមន៍ផងដែរចំពោះបញ្ហានេះ។

## ខ.៣. មន្ត្រីចុះឈ្មោះបោះឆ្នោត

### ខ.៣.១ សមាសភាព

មានភាពមិនប្រក្រតីទាក់ទងសមាសភាពនៃប្រការ១.៩ ចំណុច ១.៩.១ ចំណុច១.៩.២ និងចំណុច១.៩.៣ នៃ ប.ន.ប.ថ និងមាត្រា៥០ នៃ ច.ប.ត.រ បានបង្ហាញពីសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត ដែលក្រុមនីមួយៗមានសមាសភាពចំនួន ៣នាក់ (ប្រធាន អនុប្រធាន និងការីកុំព្យូទ័រ) សម្រាប់ឃុំសង្កាត់ដែលមានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតចំនួន៧០០០នាក់ និងលើសពីនេះតាមតាមរូបមន្តជាក់ស្តែង។

ទាក់ទងសមាសភាពមន្ត្រីចុះឈ្មោះបោះឆ្នោតនេះ អ្នកសង្កេតការណ៍សង្កេតឃើញថា មន្ត្រី ក.ច.ប នៅកន្លែងមួយចំនួន អវត្តមានមួយរយៈពេលខ្លី ដោយមូលហេតុមកយឺត អ្នកខ្លះសុំច្បាប់ឈឺ អ្នកខ្លះច្បាប់ឈប់សំរាករឿងផ្ទាល់ខ្លួន និងកន្លែងខ្លះជំនួយការអនុប្រធានរវល់ទៅយកឯកសារសម្រាប់ចុះឈ្មោះ ដែលជាហេតុធ្វើឲ្យសមាសភាពក្រុមចុះឈ្មោះត្រូវដោះដូរ និងបន្ថែមមុខងារជួយគ្នាធ្វើការ។ ករណីនេះកើតមានចំនួន ១៧៧ករណី នៃទីកន្លែងដែលខុមហ្វ្រែលបានធ្វើការសង្កេត។

### ខ.៣.២ សមត្ថភាព

ទាក់ទងសមត្ថភាពវិញ អ្នកសង្កេតការណ៍សង្កេតឃើញថា មន្ត្រី ក.ច.ប ចំណាយពេលខុសៗគ្នាក្នុងការចុះឈ្មោះ សម្រាប់អ្នកចុះឈ្មោះបោះឆ្នោតម្នាក់ ក្នុងនោះអ្នកសង្កេតការណ៍សង្កេតឃើញថា៖

- ប្រធាន ក.ច.ប ត្រូវការចំណាយពេលជាមធ្យម ២នាទី
- អនុប្រធាន ក.ច.ប ត្រូវការចំណាយពេលជាមធ្យម ៣នាទី
- និងការីកុំព្យូទ័រត្រូវការចំណាយពេលជាមធ្យម ៤នាទី
- សរុបក្នុងដំណើរការចុះឈ្មោះបោះឆ្នោតពីប្រធាន ដល់ការីកុំព្យូទ័រ អ្នកសុំចុះឈ្មោះបោះឆ្នោត ១នាក់ត្រូវការរយៈពេលជាមធ្យម ៨នាទី (ឬចន្លោះពី៦ ទៅ ១០នាទី) ទើបទទួលបានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត។

ថេរៈ វេលាចំណាយលើអ្នកចុះឈ្មោះម្នាក់




ក្នុងដំណើរការចុះឈ្មោះបោះឆ្នោតនោះ ក្រុមការងារចុះឈ្មោះបោះឆ្នោតមាននីតិវិធីក្នុងការអនុវត្តការងារតាមតួនាទី និងភារកិច្ច ដែលមានចែងក្នុងច្បាប់។ ក្នុងដំណើរការនេះ អ្នកសង្កេតការណ៍បានសង្កេតឃើញ ការបំពេញការងាររបស់មន្ត្រី ក.ច.ប ដូចខាងក្រោម៖



រូបភាព គ.ជ.ប

ប្រធាន ក.ច.ប មិនបានសម្ភាសន៍ ឬធ្វើខុសនីតិវិធីក្នុងការសម្ភាសន៍ជាមួយអ្នកសុំចុះឈ្មោះបោះឆ្នោត ករណីនេះអ្នកសង្កេតការណ៍សង្កេតឃើញ ៣១៩៤ករណី នៅក្នុងទីតាំង និងពេលវេលាដែលបានសង្កេត ការអនុវត្តនេះបានធ្វើខុសជាមួយចំណុច៤.៤.១៦ និង៤.៤.១៧ នៃ ប.ន.ប.ថ ដែលប្រធានមិនបានសាកសួរដល់អ្នកមកសុំចុះឈ្មោះបោះឆ្នោត។

ចំណែកអនុប្រធានក្រុមការងារចុះឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍បានសង្កេតឃើញថា ការសរសេរព័ត៌មានក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត គឺសរសេរខុសព័ត៌មាន ដូចជាអក្ខរាវិរុទ្ធ ក្នុងនោះសង្កេតឃើញមានចំនួន ៤៩៩ករណី ដូចជាការសរេរ ឈ្មោះ «ផ» ទៅ «ថ» ភេទប្រុសទៅជាស្រី កន្លែងខ្លះខុសភូមិជាដើម ដែលដំណើរការនេះមានចែងក្នុងចំណុច៤.៤.២០ នៃ ប.ច.ប.ថ។




## ខ.៤ ការចាត់ចែង

### ខ.៤.១ ដំណាក់កាលនៃការចុះឈ្មោះ

អ្នកសង្កេតការណ៍ខុមហ្វ្រែលបានសង្កេតឃើញថា មានករណីឃុំខ្លះមិនបានដាក់បង្ហាញប្រតិទិន្ននៃការចុះឈ្មោះបោះឆ្នោតតាមភូមិ ឃុំ ឬតាមទីសាធារណៈនោះទេ ដូចជាឃុំព្រៃខ្ពស់ ស្រុកបវេល ខេត្តបាត់ដំបង ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

### ខ.៤.២ ជំហាននៃការចុះឈ្មោះ

ភាពមិនប្រក្រតីទាក់ទិនជំហាននៃការចុះឈ្មោះបោះឆ្នោត បានកំណត់ដូចមានចែងក្នុងប្រការ៤.៤ ក្នុងចំណុច ៤.៤.១៦ រហូត ៤.៤.២២ នៃ ប.ន.ប.ថ។ ទាក់ទងជំហាននៃការចុះឈ្មោះបោះឆ្នោតនេះ អ្នកសង្កេតការណ៍បានសង្កេតឃើញថាមានយ៉ាងហោចណាស់ ៣១០ករណី ប្រធានក្រុមចុះឈ្មោះបោះឆ្នោតបានបដិសេធការសុំចុះឈ្មោះបោះឆ្នោតដោយពួកគាត់មិនបានឲ្យ«ទម្រង់បដិសេធ»ដល់អ្នកចុះឈ្មោះបោះឆ្នោត ករណីនេះមានស្ទើរគ្រប់ទីកន្លែងនៃការិយាល័យដែលអ្នកសង្កេតការណ៍បានសង្កេត ព្រមទាំងមិនបញ្ជាក់ពីមូលហេតុនៃការបដិសេធ។ រីឯករណីដែលទាក់ទងអនុប្រធាន ក.ច.ប វិញ សង្កេតឃើញមាន ១៣១៣ករណី ដែលអ្នកសង្កេតការណ៍បានសង្កេតឃើញថា អនុប្រធាន ក.ច.ប មិនបានណែនាំអ្នកសុំចុះឈ្មោះបោះឆ្នោតឲ្យទៅជួបជាមួយការីកុំព្យូទ័រ។ សម្រាប់ការីកុំព្យូទ័រ អ្នកសង្កេតការណ៍សង្កេតឃើញថា មានធ្វើការផ្ទៀងផ្ទាត់ផ្តិតស្នាមក្រយៅដៃមិនត្រឹមត្រូវផងដែរ ករណីឃើញមានចំនួន ១៦២ករណី។

**ប្រធានមិនចេញទម្រង់បដិសេធ**




**អនុប្រធានមិនមានសេចក្តីណែនាំ**




**ផ្តិតមេដៃមិនត្រឹមត្រូវ**



ទាក់ទងប្រជាពលរដ្ឋដែលបានមកចុះឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍សង្កេតឃើញថា មានអ្នកសុំចុះឈ្មោះបោះឆ្នោតខ្លះដែលបានមកចុះឈ្មោះ ហើយវិលត្រឡប់ទៅវិញដោយមិនបានទទួលនូវ«ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត» ករណីនេះសង្កេតឃើញមានចំនួន ២៣ករណី ក្នុងចំណោមនោះមាន ៣ករណី ដែលបានបង្ហាញច្បាស់ថា មន្ត្រីការីកុំព្យូទ័រមិនបានប្រគល់ឲ្យ ៣ករណីទៀតអ្នកសុំចុះឈ្មោះភ្លេច និងក្រៅពីនោះករណីផ្សេងៗដែលបញ្ជាក់មិនបានច្បាស់លាស់ពីមូលហេតុ។ ករណីទាំងនេះ កើតមានក្នុងខេត្តបន្ទាយមានជ័យ កំពង់ធំ ក្រចេះ សៀមរាប ស្វាយរៀង ប៉ៃលិន និងត្បូងឃ្មុំ។

ក្នុងដំណើរការចុះឈ្មោះ គ.ជ.ប បានដាក់អេក្រង់សម្រាប់ឲ្យអ្នកមកចុះឈ្មោះបោះឆ្នោតធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ព័ត៌មាន ទៅតាមជំហាននៃការចុះឈ្មោះបោះឆ្នោត តែជាក់ស្តែងអ្នកសង្កេតការណ៍ពិនិត្យឃើញថា ប្រជាពលរដ្ឋចំនួន ៣៧៣៩ករណី ក្នុងពេលសង្កេត គឺមិនបានផ្ទៀងផ្ទាត់ឈ្មោះរបស់ពួកគេ ជាមួយអេក្រង់កុំព្យូទ័រដែលបានដាក់បង្ហាញនោះទេ បញ្ហាដោយសារតែមន្ត្រីមិនបានណែនាំដល់ពួកគាត់ ករណីខ្លះអ្នកសុំចុះឈ្មោះមិនពិនិត្យដោយខ្លួនឯង ករណីខ្លះទៀតគាត់គ្មានជំនួយការ និងករណីចុងក្រោយគឺអ្នកចុះឈ្មោះមិនចេះអក្សរតែម្តង។

**មិនបានទទួលទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ**




**ផ្ទៀងផ្ទាត់ជាមួយអេក្រង់កុំព្យូទ័រ**




ទាក់ទងការផ្ទៀងផ្ទាត់ទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ការសង្កេតបានបង្ហាញថា ភាគច្រើនគាត់ប្រើប្រាស់ឯកសារបញ្ជាក់សញ្ញាណសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដើម្បីធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ តែទោះជាយ៉ាងណាក៏មានប្រជាពលរដ្ឋបានប្រើប្រាស់ភ្នែកទទេរ ក្នុងការមើល និងផ្ទៀងផ្ទាត់នេះផងដែរ។

នៅក្នុងបទបញ្ជា និងនីតិវិធីក្នុង ប្រការ៤.៤.២ បានកំណត់ថាប្រជាពលរដ្ឋម្នាក់មានឈ្មោះតែមួយគត់នៅក្នុងបញ្ជីឈ្មោះបោះឆ្នោតតែមួយ។ ទាក់ទងករណីនេះ អ្នកសង្កេតការណ៍បានសង្កេតឃើញថា ប្រជាពលរដ្ឋមកចុះឈ្មោះម្តងហើយបានវិលត្រឡប់មកវិញម្តងទៀត ករណីនេះកើតឡើងមានប្រហែល ៣៣ករណី ដូចជានៅក្នុងឃុំត្បែង ខេត្តព្រះវិហារ ឃុំស្តៅកោងខេត្តព្រៃវែង និងក្នុងឃុំនៃខេត្តមួយចំនួនទៀត។ តែទោះជាយ៉ាងណា យើងក៏មិនដឹងច្បាស់ថាការវិលត្រឡប់មកចុះឈ្មោះវិញម្តងទៀតនេះដោយមានមូលហេតុអ្វីច្បាស់លាស់នោះទេ។

ទាក់ទងការបញ្ជូនទិន្នន័យពីការិយាល័យចុះឈ្មោះបោះឆ្នោតមកមជ្ឈមណ្ឌលកុំព្យូទ័រ អ្នកសង្កេតការណ៍បានសង្កេតឃើញមានបញ្ហាក្នុងការបញ្ជូនព័ត៌មានរហូតដល់ ៣៨៩ករណី បញ្ហានៃការរអាក់រអួលនេះ គឺបណ្តាលមកពីសេវាអ៊ីនធឺណិតដែលមានភាពរអាក់រអួល និងបញ្ជូនយឺត។




ទាក់ទងដំណើរការនៃការចុះឈ្មោះ ដែលមានភាពរអាក់រអួលរហូតដល់បញ្ឈប់ដំណើរការ រយៈពេលចាប់ពី ៣០នាទីឡើងទៅ អ្នកសង្កេតការណ៍សង្កេតឃើញថាមាន ១០៥(០.៦៧%)ករណី ដែលបានកើតឡើង ក្នុងរយៈពេលនៃការសង្កេតនេះ ករណីដែលកើតឡើងនោះរួមមានដូចជា ឧបករណ៍ មិនដំណើរការ កម្មវិធីសម្រាប់ចុះឈ្មោះបោះឆ្នោត មានភាពរអាក់រអួលបើកមិនដំណើរការស្រួលដោយមិនស្គាល់ឧបករណ៍ជាដើម បញ្ហាទាំងនេះគេសង្កេតឃើញមាននៅក្នុងខ្លះ នៃខេត្តទាំងអស់។



## គ. ការរកឃើញរបស់ គ.ជ.ប អំពីភាពមិនប្រក្រតី និងទិន្នន័យខុស

### គ.១. ការបញ្ជូនទិន្នន័យយឺតក្រោយថ្ងៃបិទការចុះឈ្មោះ

នៅព្រឹកថ្ងៃសុក្រ ទី២៣ ខែធ្នូ ឆ្នាំ២០១៦ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)បានបានបង្ហាញពីមូលហេតុ នៃការយឺតយ៉ាវក្នុងការបញ្ជូនទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោត ចំនួន ២៣១៨ នាក់ ដែលបញ្ជូនពីឃុំចំនួន៤៣ នៃខេត្ត ចំនួន១៣ មកកាន់នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតក្រោយថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០១៦ ដែលជាថ្ងៃបិទបញ្ចប់ការចុះឈ្មោះបោះឆ្នោត។

នៅក្នុងកិច្ចប្រជុំខាងលើនេះ គ.ជ.ប ក៏បានធ្វើការបង្ហាញអោយឃើញពីចំនួនទិន្នន័យ តាមបណ្តាឃុំសង្កាត់ដែលយឺតយ៉ាវនេះ ហើយក៏បានអោយតំណាងគណបក្សនយោបាយ ធ្វើសំណាកផ្ទៀងផ្ទាត់ឈ្មោះអ្នកទាំងនោះ ដើម្បីធានាថា ឈ្មោះរបស់ពួកគេមកដល់ពេលត្រូវបាន គ.ជ.ប បញ្ចូលទៅក្នុង ប្រព័ន្ធទិន្នន័យហើយ បើទោះបីជាឈ្មោះទាំងនោះបានបញ្ជូនមកយឺតពេលក្តី។

វិធីសាស្ត្រនៅក្នុងការផ្ទៀងផ្ទាត់នោះ គ.ជ.ប បានរៀបចំបញ្ជីឈ្មោះអ្នកដែលបានបញ្ជូនមកយឺតទាំង ២៣១៨ នាក់ ដោយសម្រេចជ្រើសរើសយក ឃុំសង្កាត់ចំនួន៥ ដែលមានឈ្មោះច្រើនមកធ្វើជាសំណាក ដើម្បីធ្វើការផ្ទៀងផ្ទាត់។ នៅក្នុងមួយឃុំ គ.ជ.ប អោយតំណាងគណបក្សនយោបាយជ្រើសរើសយកឈ្មោះ ៥នាក់ មកធ្វើការផ្ទៀងផ្ទាត់ ថាឈ្មោះទាំងនោះបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យរបស់ គ.ជ.ប មកផ្ទៀងផ្ទាត់ជាមួយគល់បញ្ជីនៃបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត។

គ.ជ.ប បានបញ្ជាក់មូលហេតុថា ហេតុផលដែលនាំអោយមានការយឺតយ៉ាវក្នុងការបញ្ជូនឈ្មោះទាំងនោះមកនាយកដ្ឋានទិន្នន័យ របស់ គ.ជ.ប យឺត គឺជាកំហុសរបស់មន្ត្រីការីកុំព្យូទ័រមួយផ្នែក ពោលគឺពួកគាត់ធ្វើការងារនៅមានចន្លោះប្រហោង ព្រមទាំងការយល់ដឹងនៅមានកំរិត និងមួយផ្នែកទៀតគឺដោយសារតែប្រព័ន្ធអ៊ីនធឺណែតខ្លះ រួមផ្សំជាមួយស្ថានភាពផ្លូវលំបាក និងដាច់ស្រយាលខ្លះ។

ជាការកត់សម្គាល់ទិន្នន័យទាំងអស់នោះ មិនមានអ្វីដែលជាបញ្ហានោះទេ អ្វីដែលគេសង្កេតឃើញគឺនៅក្នុងចំណោមឈ្មោះអ្នកដែលបានធ្វើការផ្ទៀងផ្ទាត់មានម្នាក់ មានបញ្ហាត្រង់ពេលវេលានៃការចុះឈ្មោះបោះឆ្នោត ដោយគល់បញ្ជី និងប្រព័ន្ធទិន្នន័យមានការខុសគ្នាមួយថ្ងៃ (ក្នុងម៉ាស៊ីនកុំព្យូទ័រយឺតជាង ១ថ្ងៃ)។ ឈ្មោះចំនួនជាង ២៣១៨ នាក់ ដែលមិនទាន់បានបញ្ចូលទៅក្នុងបញ្ជីចុះឈ្មោះបណ្តោះអាសន្ន មាននៅក្នុងខេត្តចំនួន១៣ មានដូចជា ខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត កោះកុង ក្រចេះ ព្រះវិហារ ព្រៃវែង រតនគិរី សៀមរាប តាកែវ និងខេត្តត្បូងឃ្មុំ។

ការសង្កេតរបស់ខុមហ្វ្រែល យល់ឃើញថា ករណីនេះវាអាចកើតមាន ដោយកំហុសបច្ចេកទេសពិតមែន ម្យ៉ាងទៀតវាមិនមានអ្វីដែលជាបញ្ហាធ្ងន់ធ្ងរនោះទេ ព្រោះទិន្នន័យត្រូវបានផ្ទៀងផ្ទាត់ត្រឹមត្រូវដូចគ្នារវាងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងទិន្នន័យដែលមាននៅក្នុងកុំព្យូទ័រ រីឯ ១ករណីដែលបានរកឃើញពីពេលវេលាខុសគ្នាវាគ្រាន់តែជាពេលវេលាបញ្ជូននោះទេ។

## គ.២. ករណីឈ្មោះស្ទួន និងការខុសទិន្នន័យ

ទាក់ទងឈ្មោះស្ទួន និងភាពមិនប្រក្រតីនៃទិន្នន័យ គ.ជ.ប បានបង្ហាញថា មជ្ឈមណ្ឌលទិន្នន័យរបស់ គ.ជ.ប រកឃើញមានអ្នកចុះឈ្មោះបោះឆ្នោតដែលមានទិន្នន័យស្ទួន (ឈ្មោះស្ទួនតាមរយៈស្នាមក្រយៅដៃ និងស្ទួនតាមរយៈទិន្នន័យ(ឈ្មោះ,ភេទ, ថ្ងៃខែឆ្នាំកំណើត, និងរូបថត) មានចំនួន ១៩៣១២(មួយម៉ឺនប្រាំបួនពាន់បីរយដប់ពីរ)នាក់ ប្រហែល ៣% នៃទិន្នន័យអ្នកបានចុះឈ្មោះបោះឆ្នោតសរុប ក្នុងនោះមានឈ្មោះដែលមានទិន្និន័យដូចគ្នាទាំងស្រុងមាន ៣២៩៦ (បីពាន់ពីររយកៅសិបប្រាំមួយ)នាក់។ ក្នុងនោះចំពោះឈ្មោះដែលត្រូវលុបចោលជាង ៣ពាន់នាក់ គឺដោយសារឈ្មោះទាំងនោះបានចុះជាច្រើនកន្លែង និងមានលេខអត្តសញ្ញាណប័ណ្ណរួមទាំងទិន្និន័យទាំងនោះដូចគ្នាផងដែរ។ គ.ជ.ប បានបញ្ជាក់មូលហេតុដែលអាចបណ្តាលឲ្យមានមនុស្សម្នាក់អាចចុះបានច្រើនដងនោះគឺមកពីការចុះឈ្មោះសាកល្បង ការផ្លាស់ប្តូរទីលំនៅ ការផ្ទេរកន្លែងចុះឈ្មោះមនុស្ស ០២(ពីរ)នាក់ ប្រើប្រាស់អត្តសញ្ញាណប័ណ្ណតែមួយ និងមនុស្សម្នាក់ប្រើឯកសារបញ្ជាក់អត្តសញ្ញាណពីរ។

ករណីមួយទៀតគឺ ឈ្មោះស្ទួនដែលជាករណីគាត់ប្រើប្រាស់ អ.ខ (អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ)ផង ហើយគាត់ទៅកន្លែងផ្សេង គាត់ប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណផង បានន័យថា មនុស្សគាត់ម្នាក់ គាត់ចុះឈ្មោះច្រើនកន្លែង។ ហើយករណីរបៀបហ្នឹង បើដោយសារការស្ទួននោះជាចេតនារបស់បុគ្គលដែលព្យាយាមមានឈ្មោះលើសក្នុងបញ្ជីបោះឆ្នោតមានលើសពីពីរកន្លែង។

ចំពោះការបញ្ចូលទិន្និន័យអ្នកចុះឈ្មោះបោះឆ្នោត គ.ជ.ប រកឃើញថា មានឈ្មោះជាង ២១ម៉ឺនឈ្មោះ ត្រូវបានបញ្ចូលទន្និន័យខុស ហើយក៏បានសម្រេចកែតម្រូវទៅតាមអត្តសញ្ញាណប័ណ្ណរួចហើយផងដែរ។

ប្រព័ន្ធថ្មីមានភាពខ្លាំងមួយដែល គ.ជ.ប អាចរកឃើញបញ្ហាដែលកើតមាននៅពេលផ្ទៀងផ្ទាត់ និងការបញ្ចូលទិន្នន័យចុះឈ្មោះបោះឆ្នោតដែលមិនបានបញ្ជូនសព្វគ្រប់មកកាន់នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត ហើយ គ.ជ.ប ក៏អាចកែតម្រូវបានដែរ។

## គ.៣ ការអង្កេតលើបញ្ជីឈ្មោះបោះឆ្នោតដំបូងដែលចេញដោយ គ.ជ.ប

តាមកាលវិភាគរបស់ គ.ជ.ប បានបិទផ្សាយបញ្ជីឈ្មោះដំបូងក្នុងថ្ងៃទី៣ ខែមករា ឆ្នាំ២០១៧ និងទុកឱ្យមានការប្តឹងតវ៉ា និងប្តឹងជំទាស់លើបញ្ជីបោះឆ្នោតដំបូងទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈ១០ថ្ងៃ គឺរហូតដល់ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧។

ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះនេះ ខុមហ្វ្រែលបានសង្កេតឃើញថាប្រជាពលរដ្ឋ បានចេញទៅពិនិត្យឈ្មោះមានប្រមាណ៣០%នៅតាមសាលាឃុំ សង្កាត់។ ខេត្តដែលមានភាគរយប្រជាពលរដ្ឋចេញទៅពិនិត្យតិចជាងគេរួមមាន៖ ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តឧត្តរមានជ័យ ខេត្តព្រះសីហនុ។ ដោយឡែករាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តរតនៈគិរីជាដើម គឺមានប្រជាពលរដ្ឋចេញទៅពិនិត្យច្រើនមធ្យម។ ប្រជាពលរដ្ឋមួយចំនួនពឹងផ្អែកលើការពិនិត្យផ្ទៀងផ្ទាត់ដោយមេភូមិ ហើយសាមីខ្លួនមិនបានទៅពិនិត្យដោយផ្ទាល់ខ្លួននោះទេ។ ប្រជាពលរដ្ឋជាច្រើនបានផ្ទៀងផ្ទាត់ឈ្មោះតាមរយៈគេហទំព័របញ្ជីឈ្មោះបោះឆ្នោតរបស់ គ.ជ.ប(www.voterlist.org.kh)។

ករណីនេះ ខុមហ្វ្រែលសង្កេតឃើញថា ការផ្សព្វផ្សាយរបស់អាជ្ញាធរពាក់ព័ន្ធ (អាជ្ញាធរមូលដ្ឋាន គណៈកម្មការរៀបចំការបោះឆ្នោត (គ.ជ.ប) និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន...) មិនសូវមានភាពទូលំទូលាយ។ ការផ្សព្វផ្សាយភាគច្រើនគឺតាមមធ្យោបាយបិទផ្សាយបដានៅសាលាឃុំ សង្កាត់ និងទីប្រជុំជនមួយចំនួន ការជូនដំណឹងដល់ប្រជាពលរដ្ឋដោយមេភូមិ និងចាក់ផ្សាយតាមឧឃោសនស័ព្ទ។ នៅក្នុងអំឡុងពេលបិទបញ្ជីឈ្មោះដំបូងនេះ ចំនួនបណ្តឹងតវ៉ាលើករណីខុសឈ្មោះ ឬខុសទិន្នន័យផ្សេងៗមានចំនួនតិច។ គោលបំណងនៃបណ្តឹងនេះ វាគ្រាន់តែជាការស្នើកែតម្រូវឈ្មោះ ឬទិន្នន័យប៉ុណ្ណោះ ប៉ុន្តែប្រជាពលរដ្ឋសាមញ្ញយល់ថាមានភាពស្មុគស្មាញសម្រាប់ពួកគេនូវពេលឮថាខ្លួនត្រូវដាក់ពាក្យបណ្តឹងក្នុងករណីខុសឈ្មោះ ឬទិន្នន័យ។ សម្រាប់ដំណើរការនៃការដោះស្រាយបណ្តឹងជំទាស់អ្នកបានចុះឈ្មោះបោះឆ្នោតថា មិនមានសញ្ជាតិខ្មែរ ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ភាគច្រើន គឺមិនបានកោះហៅគូភាគី ពិសេសចុងចម្លើយមកសួរដេញដោលក្នុងការប្រជុំសម្រេចទេ។ កបឃ.ស ភាគច្រើនក៏មិនបានសួរដេញដោលចុងចម្លើយអំពីឯកសារផ្លូវច្បាប់នៃការទទួលបានសញ្ជាតិខ្មែរ ក្រៅតែពីការបង្ហាញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ចុងចម្លើយដែលភាគីដើមបណ្តឹងមានការសង្ស័យអំពីភាពត្រឹមត្រូវនៃការទទួលបានឯកសារនេះ។ លទ្ធផលនៃការដោះស្រាយរបស់ កបឃ.ស ភាគច្រើនគឺមិនយល់ព្រមតាមពាក្យបណ្តឹង ដែលប្តឹងជំទាស់ឲ្យលុបឈ្មោះអ្នកបោះឆ្នោតដែលសង្ស័យថា មិនមានសញ្ជាតិខ្មែរ។ ខុសពីដំណើរការពីមុនយ៉ាងតិចមាន ២ករណីក្នុងខេត្តព្រះវិហារ និងខេត្តសៀមរាប ចុងចម្លើយបានប្តឹងភាគីដើមបណ្តឹងទៅតុលាការវិញពីបទបរិហាកេរ្តិ៍។

ការសង្កេតបានបង្ហាញទៀតថា មានករណីបាត់ឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំមួយចំនួននៃស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ជាឧទាហរណ៍នៅក្នុងឃុំជាំក្រវៀន មានករណីបាត់ឈ្មោះអ្នកបោះឆ្នោតប្រមាណ១១១នាក់ ដែលបណ្តាលមកពីការបញ្ជូនទិន្នន័យពីឃុំ សង្កាត់មក គ.ជ.ប។ ក្រោយពីការពិនិត្យផ្ទៀងផ្ទាត់ឃើញ គ.ជ.ប បានបញ្ចូលឈ្មោះ ទាំងនោះក្នុងបញ្ជីបោះឆ្នោតដំបូង និងបានបញ្ជូនទៅឃុំ សង្កាត់ដើម្បីបិទផ្សាយជាថ្មី។

ទាក់ទងការបាត់នេះ ខុមហ្វ្រែលបានសិក្សា និងជួបជាមួយនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត ដើម្បីសិក្សាពីបញ្ហាដែលកើតឡើង អ្វីដែលជាបញ្ហាគឺ មិនមានការផ្ទៀងផ្ទាត់រវាងរបាយការណ៍បូកសរុបប្រចាំថ្ងៃនៃការចុះឈ្មោះបោះឆ្នោត ជាមួយចំនួនទិន្នន័យដែលបានផ្ញើមកនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត។ ករណីនេះជាហេតុដែល គ.ជ.ប មិនអាចគ្រប់គ្រងឈ្មោះដែលបានបាត់ ឬដឹងថាម៉ាស៊ីនចុះឈ្មោះមួយណាដែលមិនបានបញ្ជូនអស់ និងចំណុចខ្វះខាតនៃការគ្រប់គ្រងទិន្នន័យ។ ទោះបីដឹងថា មានឈ្មោះក្នុងឃុំ សង្កាត់ខ្លះបានបាត់ក៏ដោយ គ.ជ.ប នូវតែអនុវត្តតាមកាលវិភាគចេញបញ្ជីឈ្មោះបោះឆ្នោតផ្លូវការទៀតដដែល។

គួរឱ្យកត់សម្គាល់ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត បានដាក់ក្រុមការងារត្រួតពិនិត្យឈ្មោះស្ទួន និងផ្ទៀងផ្ទាត់ទិន្នន័យនៃអ្នកបោះឆ្នោតដែលបានបញ្ជូនពីឃុំ សង្កាត់ នូវរាល់ព័ត៌មានជាមួយឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកចុះឈ្មោះបោះឆ្នោតម្នាក់ៗ ដែលបានថតភ្ជាប់មកជាមួយ តែការសង្កេតឃើញថាព័ត៌មានអ្នកបោះឆ្នោតទាំងនោះនៅតែមានខុស។ ឧទាហរណ៍ក្នុងបញ្ជីឈ្មោះបោះឆ្នោតដំបូងខ្លះ មានអ្នកបោះឆ្នោតដែលមិនមានរូបថតនៅក្នុងបញ្ជី និងជំនួសដោយរូបសំបុត្រកំណើត។ ទោះបីជាមានការបិទផ្សាយបញ្ជីឈ្មោះអ្នកដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោតសម្រាប់អ្នកបោះឆ្នោតមានឈ្មោះស្ទួន នៅតាមសាលាឃុំ សង្កាត់ក៏ដោយ ក៏នៅក្នុងបញ្ជីបោះឆ្នោតដំបូងសង្កេតឃើញថា នៅមានឈ្មោះស្ទួន និងបាត់ឈ្មោះខ្លះនៅឡើយ។

## ឃ. ការវាយតម្លៃជាទូទៅនៃការឃ្លាំមើលដំណើរការចុះឈ្មោះបោះឆ្នោតពីអ្នកសង្កេតការណ៍

ជាលទ្ធផល នៅក្នុងការសង្កេតលើដំណើរការចុះឈ្មោះ អ្នកសង្កេតការណ៍ចំនួន ៥៤៦នាក់បានធ្វើការសាកសួរ និងទទួលបានចំនួន ៣២១៧ របាយការណ៍ (លទ្ធផលមិនមែនជាសំណាកនោះទេ វាគ្រាន់តែជាករណី) បានពីចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានចំនួនតិចតួចថាអំពីអវិជ្ជមាន ឬការខ្វះខាតនៃដំណើរការចុះឈ្មោះបោះឆ្នោតនេះ ដូចមាននៅខាងក្រោម៖

### ឃ.១. ចំណាប់អារម្មណ៍របស់មន្ត្រី ក.ច.ប

ការជួបសន្ទនាជាមួយមន្ត្រី ក.ច.ប ជាលទ្ធផលបានបង្ហាញឲ្យឃើញថា ក្រុមការងារចុះឈ្មោះបោះឆ្នោត ចំនួន ៤% ដែលយើងទទួលបាន គឺគាត់មិនសូវសប្បាយចិត្តនោះទេ ព្រោះគាត់បង្ហាញអារម្មណ៍ថា ប្រជាពលរដ្ឋមកចុះឈ្មោះមិនសូវច្រើននៅកន្លែងខ្លះ និងកន្លែងខ្លះទៀតគឺ បញ្ហាររអាករអួលនៃប្រព័ន្ធកុំព្យូទ័រ។

### ឃ.២. អារម្មណ៍របស់អ្នកសង្កេតការណ៍ដទៃណាម្នាក់

សម្រាប់អ្នកសង្កេតការណ៍ដែលមានវត្តមាននៅទីនោះវិញ ២.៥% បានបង្ហាញពីអារម្មណ៍មិនសប្បាយចិត្ត ដោយសារពួកគាត់មើលឃើញថាប្រជាពលរដ្ឋ មិនមកចុះឈ្មោះបោះឆ្នោតច្រើន និងកន្លែងខ្លះភ្លៀងខ្លាំងមិនអាចឲ្យប្រជាពលរដ្ឋមកចុះឈ្មោះបានស្រួល។

### ឃ.៣. ចំណាប់អារម្មណ៍របស់ភ្នាក់ងារគណបក្សនយោបាយណាម្នាក់

សម្រាប់ភ្នាក់ងារគណបក្សនយោបាយបានសម្តែងអារម្មណ៍របស់គាត់ក៏មិនខុសពីអ្នកសង្កេតការណ៍ និងមន្ត្រី ក.ច.ប នោះទេគឺ ២.៨% សម្តែងការមិនពេញចិត្ត ព្រោះគាត់មើលឃើញថាប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់គាត់មកចុះឈ្មោះបោះឆ្នោតមានចំនួនតិច និងម្យ៉ាងទៀតប្រជាពលរដ្ឋរបស់គាត់បានធ្វើការចំណាកស្រុកច្រើន។

### ឃ.៤. ចំណាប់អារម្មណ៍ផ្ទាល់របស់អ្នកសង្កេតការណ៍រយៈពេលមួយថ្ងៃ

សម្រាប់អ្នកសង្កេតការណ៍ គាត់មានអារម្មណ៍សប្បាយចិត្តច្រើន និងមានតែ ៣.៧%ទេ ដែលគាត់មិនសប្បាយចិត្តដោយសារតែ ចុងក្រោយនៃការចុះឈ្មោះបោះឆ្នោតគាត់មើលឃើញថាមន្ត្រីចុះឈ្មោះបោះឆ្នោតមិនសូវយកចិត្តទុកដាក់ចំពោះការងារ ហើយម្យ៉ាងទៀតរយៈពេលចុងក្រោយនេះឃើញថាប្រជាពលរដ្ឋសម្រុកចុះឈ្មោះច្រើន។

# ឧបសម្ព័ន្ធ

## ១. លិខិតស្នើសុំបង្កើតការិយាល័យ ០៧៨១ ពីមេឃុំស្វាយជុក



## ២. លិខិតដែលសមាគមអាដហុកដាក់ជូន និងការឆ្លើយតបពីសាលាខេត្តកណ្ដាល



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកណ្ដាល

កណ្ដាល, ថ្ងៃទី ខែ ឆ្នាំ២០១៦

ជម្រាបមក

លោក ប្រធានសមាគមអាដហុកខេត្តកណ្ដាល

កម្មវត្ថុ : ស្ដីពីសំណើសុំកិច្ចសហការបើកវគ្គអប់រំផ្សព្វផ្សាយ និងកម្មវិធីសន្ទនាពាក់ព័ន្ធនឹងសិទ្ធិបោះឆ្នោតដល់ប្រជាពលរដ្ឋក្នុងគោលដៅ ដើម្បីបង្កើន និងគាំទ្រចំនួនប្រជាពលរដ្ឋចូលរួមក្នុងដំណើរការបោះឆ្នោត នៅគ្រប់ស្រុកក្នុងខេត្តកណ្ដាល។

យោង : លិខិតលេខ ០២៧ អាដហុក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ របស់សមាគម អាដហុក។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបមកលោក ប្រធានសមាគម ជ្រាបថា៖ រដ្ឋបាលខេត្ត បានទទួលរួចហើយនូវលិខិតស្នើសុំអនុញ្ញាត និងផ្ដល់កិច្ចសហការដល់សមាគមក្នុងដំណើរការសកម្មភាពបើកវគ្គអប់រំផ្សព្វផ្សាយ និងកម្មវិធីសន្ទនាពាក់ព័ន្ធនឹងសិទ្ធិបោះឆ្នោតដល់ប្រជាពលរដ្ឋក្នុងគោលដៅ ដើម្បីបង្កើន និងគាំទ្រចំនួនប្រជាពលរដ្ឋចូលរួមក្នុងដំណើរការបោះឆ្នោត នៅគ្រប់ស្រុកក្នុងខេត្តកណ្ដាល។ ចំពោះករណីនេះ រដ្ឋបាលខេត្ត ស្នើឲ្យលោកប្រធានសមាគមសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃ ជាមុនសិន។

អាស្រ័យហេតុនេះ សូមលោក ប្រធានសមាគម ជ្រាបតាមការគួរ។

សូមលោក ប្រធានសមាគម ទទួលនូវការគោរពអំពីខ្ញុំ។

អភិបាលខេត្ត



សមាគមអាដហុក

Mobile : 011 858 760 / 016 858 760 / 097 715 6000

កណ្ដាល,ថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៦

សមាគមអាដហុក ខេត្តកណ្ដាល

សូមគោរពចូលមក

ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកណ្ដាល

## ៣. លិខិតអន្តរាគមន៍ពី គ.ជ.ប ទៅក្រសួងមហាផ្ទៃចំពោះទាហានចុះឈ្មោះបោះឆ្នោត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ១០៣១/១៦ គ.ជ.ប

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**

**កម្មវត្ថុ** : សំណើមានវិធានការ និងអន្តរាគមន៍ដល់អង្គភាព នគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលមានមូលដ្ឋានឈរជើង ឬបំពេញបេសកកម្មនៅក្នុងរាជធានី ខេត្តទូទាំងប្រទេស ចាត់ចែងឱ្យនគរបាលជាតិ និងយោធិនទៅចុះឈ្មោះបោះឆ្នោត ដោយអនុវត្តឱ្យបានត្រឹមត្រូវស្របតាមច្បាប់បោះឆ្នោត ។

**យោង** :
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦

តបតាមកម្មវត្ថុ និងយោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមគោរពជម្រាបជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** ជ្រាបថា កន្លងមក គ.ជ.ប បានទទួលពាក្យបណ្តឹងមួយចំនួនទាក់ទងនឹងការចេញលិខិតបញ្ជាក់ទីលំនៅរបស់អាជ្ញាធរឃុំ សង្កាត់ ឱ្យយោធិននៅក្នុងខេត្តព្រះវិហារ និងខេត្តសៀមរាប ។ ការចេញលិខិតបញ្ជាក់ទីលំនៅមិនស្ថិតក្រោមសមត្ថកិច្ចរបស់ គ.ជ.ប ទេ ប៉ុន្តែក្រោយពីមានពាក្យបណ្តឹង គ.ជ.ប បានចុះអង្កេតស្វែងរកការពិត ហើយករណីនេះ គ.ជ.ប បានសរសេរលិខិតឆ្លើយតបទៅដើមបណ្តឹង និងធ្វើលិខិតណែនាំរំលឹកក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យរំលឹកអាជ្ញាធរឃុំ សង្កាត់ អនុវត្តឱ្យបានត្រឹមត្រូវតាមប្រកាសលេខ ១០២៤៥ ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត ។

គ.ជ.ប យល់ឃើញថា នគរបាលជាតិ ឬយោធិន ឬសន្តិសុខបោះឆ្នោត ដែលត្រូវការសុំលិខិតបញ្ជាក់ទីលំនៅសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតមាន ៣ ប្រភេទ គឺ ៖

១- នគរបាលជាតិ ឬយោធិន ក្នុងមូលដ្ឋានឈរជើង ដែលស្ថិតនៅក្នុងភូមិសាស្ត្រឃុំ សង្កាត់ ហើយដែលត្រូវសុំចុះឈ្មោះបោះឆ្នោត ។

-១-

២- នគរបាលជាតិ ឬយោធិន ឬសន្តិសុខបោះឆ្នោត បំពេញបេសកកម្មរយៈពេលយូរហួតដល់ថ្ងៃបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៣- កម្លាំងសន្តិសុខបោះឆ្នោត ដែលត្រូវមានបេសកកម្មការពារសន្តិសុខនៅថ្ងៃបោះឆ្នោត នៅតាមការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ។

ផ្អែកតាមចំណុច ៥.៥.៧ នៃបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប បានចែងថា ប្រជាពលរដ្ឋ ឬកម្មករ សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល នាយ ឬពលនៃកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ និងបព្វជិតសាសនា ដែលកំពុងស្នាក់នៅក្នុងឃុំ សង្កាត់ណាមួយសុទ្ធតែអាចសុំចុះឈ្មោះបោះឆ្នោតនៅក្នុង ឃុំ សង្កាត់នោះ ។

ដើម្បីឱ្យស្របទៅតាមលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត និងឱ្យបញ្ជីបោះឆ្នោតមានភាពត្រឹមត្រូវ គ.ជ.ប យល់ឃើញថា គួរប្រធានអង្គភាពឈរជើងផ្តល់កិច្ចសហការក្នុងការចេញលិខិតបញ្ជាក់ជូនកងកម្លាំងទាំង ៣ប្រភេទខាងលើ ដល់អាជ្ញាធរឃុំ សង្កាត់ ដើម្បីមានមូលដ្ឋានក្នុងការចេញលិខិតបញ្ជាក់ទីលំនៅ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ដែលជាផ្នែកមួយនៃការអនុវត្តឱ្យបានត្រឹមត្រូវស្របតាមប្រកាសលេខ ១០២៥៥ ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរ ឃុំ សង្កាត់ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត និងសេចក្តីណែនាំលេខ ០១៨ សណន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។

អាស្រ័យហេតុនេះ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍** មានវិធានការ និងអន្តរាគមន៍ដល់អង្គភាពពាក់ព័ន្ធតាមការគួរ។

សូម **សម្តេចក្រឡាហោម** ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក

-២-

## ៤. លិខិតអន្តរាគមន៍ដល់អង្គភាព នគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ១០៣១/១៦ គ.ជ.ប

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**

**កម្មវត្ថុ** : សំណើមានវិធានការ និងអន្តរាគមន៍ដល់អង្គភាព នគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលមានមូលដ្ឋានឈរជើង ឬបំពេញបេសកកម្មនៅក្នុងរាជធានី ខេត្តទូទាំងប្រទេស ចាត់ចែងឱ្យនគរបាលជាតិ និងយោធិនទៅចុះឈ្មោះបោះឆ្នោត ដោយអនុវត្តឱ្យបានត្រឹមត្រូវស្របតាមច្បាប់បោះឆ្នោត ។

**យោង** :
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦

តបតាមកម្មវត្ថុ និងយោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមគោរពជម្រាបជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** ជ្រាបថា កន្លងមក គ.ជ.ប បានទទួលពាក្យបណ្តឹងមួយចំនួនទាក់ទងនឹងការចេញលិខិតបញ្ជាក់ទីលំនៅរបស់អាជ្ញាធរឃុំ សង្កាត់ ឱ្យយោធិននៅក្នុងខេត្តព្រះវិហារ និងខេត្តសៀមរាប ។ ការចេញលិខិតបញ្ជាក់ទីលំនៅមិនស្ថិតក្រោមសមត្ថកិច្ចរបស់ គ.ជ.ប ទេ ប៉ុន្តែក្រោយពីមានពាក្យបណ្តឹង គ.ជ.ប បានចុះអង្កេតស្វែងរកការពិត ហើយករណីនេះ គ.ជ.ប បានសរសេរលិខិតឆ្លើយតបទៅដើមបណ្តឹង និងធ្វើលិខិតណែនាំរំលឹកក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យរំលឹកអាជ្ញាធរឃុំ សង្កាត់ អនុវត្តឱ្យបានត្រឹមត្រូវតាមប្រកាសលេខ ១០២៤៥ ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត ។

គ.ជ.ប យល់ឃើញថា នគរបាលជាតិ ឬយោធិន ឬសន្តិសុខបោះឆ្នោត ដែលត្រូវការសុំលិខិតបញ្ជាក់ទីលំនៅសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតមាន ៣ ប្រភេទ គឺ ៖

១- នគរបាលជាតិ ឬយោធិន ក្នុងមូលដ្ឋានឈរជើង ដែលស្ថិតនៅក្នុងភូមិសាស្ត្រឃុំ សង្កាត់ ហើយដែលត្រូវសុំចុះឈ្មោះបោះឆ្នោត ។

-១-

២- នគរបាលជាតិ ឬយោធិន ឬសន្តិសុខបោះឆ្នោត បំពេញបេសកកម្មរយៈពេលយូររហូតដល់ថ្ងៃបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៣- កម្លាំងសន្តិសុខបោះឆ្នោត ដែលត្រូវមានបេសកកម្មការពារសន្តិសុខនៅថ្ងៃបោះឆ្នោត នៅតាមការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ។

ផ្អែកតាមចំណុច ៤.៤.៧ នៃបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប បានចែងថា ប្រជាពលរដ្ឋ ឬកម្មករ សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល នាយ ឬពលនៃកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ និងបព្វជិតសាសនា ដែលកំពុងស្នាក់នៅក្នុងឃុំ សង្កាត់ណាមួយសុទ្ធតែអាចសុំចុះឈ្មោះបោះឆ្នោតនៅក្នុង ឃុំ សង្កាត់នោះ ។

ដើម្បីឱ្យស្របទៅតាមលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត និងឱ្យបញ្ជីបោះឆ្នោតមានភាពត្រឹមត្រូវ គ.ជ.ប យល់ឃើញថា គួរប្រធានអង្គភាពឈរជើងផ្តល់កិច្ចសហការក្នុងការចេញលិខិតបញ្ជាក់ជូនកងកម្លាំងទាំង ៣ប្រភេទខាងលើ ដល់អាជ្ញាធរឃុំ សង្កាត់ ដើម្បីមានមូលដ្ឋានក្នុងការចេញលិខិតបញ្ជាក់ទីលំនៅ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ដែលជាផ្នែកមួយនៃការអនុវត្តឱ្យបានត្រឹមត្រូវស្របតាមប្រកាសលេខ ១០២៤៥ ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរ ឃុំ សង្កាត់ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត និងសេចក្តីណែនាំរូមលេខ ០១៨ សណនចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។

អាស្រ័យហេតុនេះ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍** មានវិធានការ និងអន្តរាគមន៍ដល់អង្គភាពពាក់ព័ន្ធតាមការគួរ។

សូម **សម្តេចក្រឡាហោម** ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក

## ៥. លិខិតឆ្លើយតបជូនគណបក្សសង្គ្រោះជាតិចំពោះការអប់រំអ្នកចុះឈ្មោះបោះឆ្នោត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ៨៦៤/១៦ គ.ជ.ប

**ជម្រាបជូន**
**ឯកឧត្តម យឹម សុវណ្ណ ប្រធានគណៈកម្មាធិការប្រតិបត្តិ**
**គណបក្សសង្គ្រោះជាតិ**

**កម្មវត្ថុ** : ស្តីពីការជួយសម្រួលការងារផ្សព្វផ្សាយជាសាធារណៈតាមបណ្តាឃុំ សង្កាត់ពីដំណើរការនៃការចុះឈ្មោះបោះឆ្នោត។

**យោង** : - សេចក្តីអំពាវនាវរបស់ គ.ជ.ប លេខ ៦៨៨/១៦ គ.ជ.ប ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦។
- លិខិតរបស់គណបក្សសង្គ្រោះជាតិលេខ ១៧៩០/១៦ គ.ស.ជ. ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនថា ៖

ទី១- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមថ្លែងអំណរគុណចំពោះគណបក្សសង្គ្រោះជាតិ ដែលបានចូលរួមជួយផ្សព្វផ្សាយការចុះឈ្មោះបោះឆ្នោត តាមការអំពាវនាវរបស់ គ.ជ.ប។

ទី២- ក្នុងការផ្សព្វផ្សាយ ស្នើគណបក្សសង្គ្រោះជាតិធ្វើការផ្សព្វផ្សាយ តែខ្លឹមសារការចុះឈ្មោះបោះឆ្នោត ដែលបានចេញដោយ គ.ជ.ប តែប៉ុណ្ណោះ ដោយពុំត្រូវបន្ថែមបន្ថយខ្លឹមសារផ្សេងទៀតដែលមានន័យឃោសនាផ្សព្វផ្សាយពាក់ព័ន្ធនឹងបញ្ហានយោបាយ ដូចជំណាក់កាលឃោសនាបោះឆ្នោតនោះទេ។

ទី៣- ដើម្បីរក្សាភាពល្អជាមួយអាជ្ញាធរមានសមត្ថកិច្ច ដែលស្ថិតនៅតាមទីកន្លែងដែលឯកឧត្តមចង់ធ្វើការផ្សព្វផ្សាយ ស្នើឯកឧត្តមសុំការអនុញ្ញាតពីអាជ្ញាធរទាំងនោះ ដើម្បីឱ្យគេចូលរួមទទួលខុសត្រូវធ្វើការការពារសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈផង។

សូមឯកឧត្តម ទទួលនូវការស្រឡាញ់រាប់អានពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

**ស៊ិក ប៊ុនហុក**

## ៦. លិខិតឆ្លើយតបរបស់ គ.ជ.ប ទៅគណបក្សសង្គ្រោះជាតិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខៈ** ១០២៤/១៦ **គ.ជ.ប**

**សូមជម្រាបជូន**

**ឯកឧត្តម កឹម សុខា ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ**

**កម្មវត្ថុ** : ករណីគណបក្សសង្គ្រោះជាតិស្នើសុំ គ.ជ.ប ជួយធ្វើអន្តរាគមន៍ ដើម្បីឱ្យពលករខ្មែរដែលធ្វើការងារនៅប្រទេសថៃ បានចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ដែលស្ថិតនៅក្នុងឃុំ សង្កាត់តាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

**យោង** : -ប្រកាសលេខ ១០២៨៥ ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត របស់ក្រសួងមហាផ្ទៃ។

-លិខិតលេខ ១៨០៥/១៦ គ.ស.ជ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ របស់គណបក្សសង្គ្រោះជាតិ។

តាមកម្មវត្ថុ និងយោងខាងលើ គ.ជ.ប បានទទួលលិខិតរបស់ឯកឧត្តមហើយ និងក្រោយពីបានពិនិត្យយ៉ាងយកចិត្តទុកដាក់ គ.ជ.ប សូមជម្រាបជូនឯកឧត្តមជ្រាបថា គ.ជ.ប មិនមានសិទ្ធិអំណាចធ្វើអន្តរាគមន៍ឱ្យមានការចុះឈ្មោះបោះឆ្នោតណាមួយ ដែលមិនបានបំពេញលក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោតតាមការកំណត់នៃច្បាប់ និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ឡើយ។ ទាក់ទងនឹងការចេញលិខិតបញ្ជាក់ទីលំនៅ គ.ជ.ប បានសម្រេចស្នើសុំអន្តរាគមន៍ទៅក្រសួងមហាផ្ទៃតាមលិខិតលេខ ១០២៣ គ.ជ.ប ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ដើម្បីធ្វើការណែនាំទៅអាជ្ញាធរឃុំ សង្កាត់ឱ្យពង្រឹងការអនុវត្តការចេញលិខិតបញ្ជាក់ទីលំនៅ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត ឱ្យបានត្រឹមត្រូវតាមប្រកាសដូចបានចុះក្នុងយោងខាងលើ។ ជាមួយគ្នានេះ គ.ជ.ប លើកទឹកចិត្ត និងបង្គលក្ខណៈដល់ប្រជាពលរដ្ឋខ្មែរ ដែលមានសិទ្ធិបោះឆ្នោតទាំងអស់ឱ្យចុះឈ្មោះបោះឆ្នោតបានត្រឹមត្រូវតាមច្បាប់ និងបទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦។

គ.ជ.ប សូមថ្លែងអំណរគុណចំពោះគណបក្សសង្គ្រោះជាតិ ដែលបានចូលរួមជំរុញឱ្យការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ប្រព្រឹត្តទៅបានរលូន ដើម្បីធានានូវសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាជ្រាបតាមការគួរ ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក